# មជ្ឈមណ្ឌលឯកសារកម្ពុជា

## លី ហ៊ី ហៅ អ៊ា ហ៊ី ភេទប្រុស (រស់) D21191

## តួនាទីៈ អ្នកទោសស-២១

## សម្ភាសជាមួយឈ្មោះ លី ហ៊ី ហៅ អ៊ា ហ៊ី អាយុ៥៧ឆ្នាំ ជាម្ចាស់ប្រវត្តិរូប រស់នៅភូមិភ្នំតូច ឃុំភ្នំតូច ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៨

## សម្ភាសដោយៈ វ៉ាន់ថាន់ ពៅដារ៉ា និង ឡុង ដានី

## សរុបៈ ៣៣ទំព័រ

**ផ្នែក«ក»**

ដានី ៖ ជំរាបសួរខ្ញុំចង់ស្គាល់ឈ្មោះពូៗពេញ ឈ្មោះអីទៅ?

ហ៊ី ៖ អើយ! ឈ្មោះ ហ៊ី ។

ដានី ៖ ត្រកូល?

ហ៊ី ៖ អឺ! ដាក់តាមជីតាអ៊ា ។

ដានី ៖ អ៊ា?

ហ៊ី ៖ បាទ! ឪពុកលី បើសព្វថ្ងៃឈ្មោះបច្ចុប្បន្នឈ្មោះ លី ហ៊ី ។

ដានី ៖ លី ហ៊ី?

ហ៊ី ៖ បាទ!

ដានី ៖ ពីមុនជំនាន់ខ្មែរក្រហម ពូដាក់អ៊ា ហ៊ី?

ហ៊ី ៖ បាទ!

ដានី ៖ សព្វថ្ងៃពូអាយុប៉ុន្មានហើយ?

ហ៊ី ៖ ៥០ប៉ុន្មាន ៥៧ ៥៨ហើយ បែប៥៨ដែរ ។

ដានី ៖ ពូកើតឆ្នាំអីគេឆ្នាំខ្មែរយើង?

ហ៊ី ៖ អត់ចាំដែរ ។

ដានី ៖ ឆ្នាំសត្វអីគេ?

ហ៊ី ៖ សត្វៗស្វា អីគេមិនមែនទេ រោងៗ ។

ដានី ៖ ឆ្នាំរោង?

ហ៊ី ៖ បាទ!

ដានី ៖ ពូស្រុកកំណើតកើតជាពូ នៅក្នុងភូមិឃុំស្រុកអីដែរ?

ហ៊ិ ៖ ភូមិព្រែកស្ដី ស្រុកកោះធំ ខេត្តកណ្ដាល ។

ដានី ៖ ភូមិៗ?

ហ៊ិ ៖ ភូមិព្រែកស្ដី ឃុំព្រែកស្ដី ស្រុកកោះធំ ខេត្តកណ្ដាល ។

ដានី ៖ ឪពុកពូឈ្មោះអីទៅ?

ហ៊ិ ៖ លី ។

ដានី ៖ ឪពុកឈ្មោះ?

ហ៊ិ ៖ អ៊ា លី ។

ដានី ៖ ម្ដាយ?

ហ៊ិ ៖ សេន ម៉ៅ ។

ដានី ៖ ពួកគាត់ទាំងពីរសព្វថ្ងៃនៅរស់ នៅស្រុកកំណើតឬយ៉ាងម៉េច?

ហ៊ិ ៖ នៅ គាត់ស្លាប់អស់ហើយ ស្លាប់នៅស្រុកកំណើត ។

ដានី ៖ ស្លាប់ក្រោយ៧៩?

ហ៊ិ ៖ បាទ!

ដានី ៖ ពូមានបងប្អូនបង្កើតទាំងអស់ប៉ុន្មាននាក់ដែរ?

ហ៊ិ ៖ ៨នាក់ ។

ដានី ៖ ស្រីប៉ុន្មានដែរ?

ហ៊ិ ៖ ស្រី៥ ប្រុស៣ ។

ដានី ៖ ពូកូនទីប៉ុន្មាន?

ហ៊ិ ៖ កូនទី២ ។

ដានី ៖ គ្រួសារពូសព្វថ្ងៃ គាត់ឈ្មោះអីដែរ?

ហ៊ិ ៖ ឈ្មោះឡូ គីមស៊ី ។

ដានី ៖ ឡូ គីមស៊ី?

ហ៊ិ ៖ បាទ!

ដានី ៖ គាត់អាយុប៉ុន្មានដែរសព្វថ្ងៃ?

ហ៊ិ ៖ អាយុ៥៣ ។

ដានី ៖ ស្រុកកំណើតគាត់នៅជាមួយ?

ហ៊ៈ នៅជាមួយគ្នា ។

ដានីៈ នៅជាមួយពូដែរ នៅព្រែកស្ដីជាមួយគ្នា?

ហ៊ៈ បាទ!

ដានីៈ ពូមានកូនចៅទាំងអស់ប៉ុន្មាននាក់ដែរ?

ហ៊ៈ ៦ ។

ដានីៈ ៦នាក់ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ហ៊ៈ ស្រី៣ ប្រុស៣ ។

ដានីៈ ពូសព្វថ្ងៃ ពូរស់នៅភូមិឃុំស្រុកអីដែរ សព្វថ្ងៃនឹង?

ហ៊ៈ ភូមិភ្នំតូច ឃុំភ្នំតូច ស្រុកអង្គរបូរី ខេត្តបន្ទាយមានជ័យ ។

ដានីៈ សព្វថ្ងៃពូប្រកបមុខរបររកស៊ីធ្វើអីដែរ?

ហ៊ៈ លក់ដូរ លក់ខ្ទឹម លក់ប៊ីចេង ។

ដានីៈ អញ្ចឹងខ្ញុំចង់ឲ្យពូរៀបរាប់ពីប្រវត្តិពូត្រួសៗ តាំងពីពូនៅក្មេងពូធ្លាប់បានរៀនសូត្រដល់ណា បន្ទាប់ពីរៀនសូត្រហើយពូធ្វើអី តាមដំណាក់ៗជាសង្ខេប?

ហ៊ៈ កាលពីមុនខ្ញុំនៅពីតូច ខ្ញុំនៅជួបជុំឪពុកម្ដាយនឹង ខ្ញុំនៅបានរៀនដល់សម័យប៉ុលពតនឹងឆ្នាំ ៧៥ ៧៦នឹងក៏គេឲ្យខ្ញុំចូលធ្វើជា គេយកខ្ញុំទៅនៅមន្ទីរធ្វើឆ្នាំងធ្វើនឹងណា បាទ! ។ រួចហើយ ដល់ចេញពីនឹងទៅទៀត គេឲ្យខ្ញុំទៅធ្វើជាកងយោធា ។

ដារ៉ាៈ ចុះកាលដែលរៀន ពូរៀនបានថ្នាក់ទីប៉ុន្មាន?

ហ៊ៈ ថ្នាក់ទី៩ ។

ដានីៈ ទី៩ពីសង្គមនឹង?

ហ៊ៈ បាទៗ ។

ដារ៉ាៈ មានន័យថាចេះអានចេះសរសេរហើយ?

ហ៊ៈ ចេះៗដែរ ។

ដារ៉ាៈ ហើយពេលដែលឲ្យទៅធ្វើកន្លែងដែលស្លឆ្នាំង ស្លអីអានឹងនៅភូមិឃុំអីដែរ?

ហ៊ៈ កោះខែលនឹង គេហៅស្ទឹងនឹង កោះខែលនឹង កោះខែលទឹកវិល ។

ដារ៉ាៈ អូ! ភូមិកោះខែលនឹង?

ហ៊ៈ បាទៗ ។

ដារ៉ាៈ នៅកន្លែងមន្ទីរស្លឆ្នាំងនឹង?

ហ៊ី ៖ បាទៗ មន្ទីរស្នូឆ្នាំងនឹង ។

ដារ៉ា ៖ ហើយកាលនឹងពូចូលមានគ្នាប៉ុន្មាននាក់ ប៉ុន្មានអី ហើយមូលហេតុអីបានពូចូលអីយ៉ាងម៉េចដែរ?

ហ៊ី ៖ កាលនឹងគេនាំដឹកនាំចូលទៅមិនមែននេះទេ គេឲ្យយើងចូលទៅម៉ង ឲ្យចូលធ្វើជាអាកន្លែងមន្ទីរនឹងសិនទៅ ធ្វើឆ្នាំង គេប្រាប់ដឹកនាំធ្វើឆ្នាំង ធ្វើបានអញ្ចឹងណា នៅកន្លែងមន្ទីរនឹង ។

ដារ៉ា ៖ ឆ្នាំណាកាលនឹងពូ?

ហ៊ី ៖ កាលឆ្នាំ៧៥នឹងដែរនឹង អឺ!ក្នុង៧០ ៧៤ ៧៥នេះ ។

ដានី ៖ បន្តពីកន្លែងធ្វើឆ្នាំងនឹង?

ហ៊ី ៖ ក៏គេឲ្យយើងទៅធ្វើជាយោធា គេគំរាមចេញពីមន្ទីរនឹងទៅទៀតណា ឲ្យយើងទៅធ្វើយោធា ។

ដារ៉ា ៖ ពូធ្វើការកន្លែងស្នូឆ្នាំងនឹង បានរយៈពេលប៉ុន្មានខែ ប៉ុន្មានឆ្នាំ?

ហ៊ី ៖ បានយូរដែរនឹង ប្រហែល៤-៥ខែ ។

ដារ៉ា ៖ ហើយនៅកន្លែងធ្វើឆ្នាំងនឹងគេមាន ខ្មែរក្រហមមានបំពាក់បំប៉នអីរៀនសូត្ររៀនអីទេ?

ហ៊ី ៖ គេឲ្យយើងរៀនសូត្រ ។

ដារ៉ា ៖ រៀនសូត្រពីអីទៅ?

ហ៊ី ៖ ពីនយោបាយគេ ឲ្យពីនយោបាយគេរៀនស្អីៗគេសព្វបែបសព្វយ៉ាងទាំងអស់នឹង ។

ប្រពន្ធ ៖ រៀនពីវិន័យបដិវត្តកាលពីសម័យនឹងណា ចា៎ស!វិន័យបដិវត្តគេនោះ ។

ដារ៉ា ៖ រៀនទៅ ខ្មែរក្រហមមានជាគ្រូ ជាអីចុះមកបង្រៀនអីអញ្ចឹងដែរ?

ហ៊ី ៖ ប្រធានគេនឹង ។

ដារ៉ា ៖ ប្រធានកន្លែងនឹង?

ហ៊ី ៖ បាទ! ប្រធានកន្លែង ។

ដារ៉ា ៖ ហើយប្រធានកាលនឹងឈ្មោះអី ពូ?

ហ៊ី ៖ ភ្លេចឈ្មោះអីដែរហើយ ភ្លេចឈ្មោះគាត់ ។

ដារ៉ា ៖ ហើយអញ្ចឹងទៅទាហាន?

ហ៊ី ៖ បាទ! ក៏គេជំរឿនចេញពីកន្លែងនឹង ឲ្យទៅធ្វើចូលជាយោធា ។

ដារ៉ា ៖ យោធា?

ហ៊ី ៖ បាទ!

ដារ៉ា ៖ ជានៅក្នុងកងអីទៅ?

ហ៊ី ៖ កង១១៩ វរៈ១១៩ ។

ដាវ៉ា ៖ វរៈ១១៩ ជាវរសេនាធំ ឬវរសេនាតូច?

ហ៊ី ៖ វរសេនាធំ ។

ដាវ៉ា ៖ វរសេនាធំនោះ?

ហ៊ី ៖ ហ៊ោ! វរសេនាតូច១០០អឺ! ហ្នឹងវរសេនាធំ១១៩ ។

ដាវ៉ា ៖ ជាកងវរសេនាធំនឹង អ្នកណាជាមេបញ្ជាការអី?

ហ៊ី ៖ អឺ! ឈ្មោះសុទ្ធ ។

ដាវ៉ា ៖ ឈ្មោះសុទ្ធ?

ហ៊ី ៖ បាទ!

ដាវ៉ា ៖ វរសេនាធំ១១៩ នៅក្នុងកងពលអីពូ?

ហ៊ី ៖ កងពលប៉ុន្មានអីទេ កាលនឹងខ្ញុំមិនបានចាំដែរនឹង ក៏បន្ទាប់ពីនឹងមកគេឲ្យបញ្ជូនមកវ៉ៃនៅព្រែកប្រា វ៉ៃនៅបែកចានអីនឹង ឲ្យងាប់ស្លាប់ខ្លាំងពេកក៏ខ្ញុំរត់មកឲ្យផ្ទះ ។

ដាវ៉ា ៖ កាលដែលទៅកងវរសេនាសធំ១១៩ ទៅគ្នាច្រើនទេ ឬក៏?

ហ៊ី ៖ ច្រើនម៉ាវរៈទាំងអស់ ។

ដាវ៉ា ៖ ចង់និយាយ ពេលចេញពីកន្លែងធ្វើឆ្នាំង ធ្វើចាន?

ហ៊ី ៖ ទៅគ្នាប៉ុន្មាននាក់ ដែលឈ្មោះប៉ុន្មាននាក់នឹង ៣-៤-៥នាក់ ។

ដាវ៉ា ៖ ៣-៤-៥នាក់ ដែលឈ្មោះមាននៅក្នុង?

ហ៊ី ៖ បាទ! ឈ្មោះបញ្ចេញពីមន្ទីរ១ធ្វើឆ្នាំង ធ្វើចាននឹងឲ្យចេញចូលធ្វើយោធា ។

ដានី ៖ ហើយសមរភូមិទី១ដែលពូចូលនឹង សមរភូមិមួយណា?

ហ៊ី ៖ សមរភូមិច្រើនណាស់ មើលតាំងពីនៅខាងជួរជងទន្លេមេគង្គ ពាមរាំង ពាមអីនឹងខ្ញុំធ្លាប់ទៅទាំងអស់ ម៉ាជួរមាត់ទន្លេបាសាក់យើងនេះវិញ តាំងពីសិតត្បូអីឡើងនឹង ហើយម៉ាជួរខាងថ្នល់នេះចេញមកបែកចាន បាទ!បែកចាន ។

ដាវ៉ា ៖ កាលនឹងវ៉ៃរបៀបប្រទាញប្រទុងពួកខ្មែរក្រហមជាមួយលន់នល់អីនឹង?

ហ៊ី ៖ បាទៗ ភ្នំបាសិតភ្នំអីនេះ ។

ដាវ៉ា ៖ សុទ្ធតែជួរសមរភូមិពូប្រឡូកនឹង?

ហ៊ី ៖ បាទ! ហើយនឹងម៉ាស្លាប់ខ្លាំង ស្លាប់ចង់អស់នៅសល់តែម៉ាកងតូច ។

ដាវ៉ា ៖ ម៉ាកងតូច?

ហ៊ី ៖ បាទ! ស្លាប់អស់ ។

ដារ៉ា ៖ បើនិយាយទៅម៉ាវរសេនាធំនឹងមានទ័ព ចំនួនទ័ពច្រើនណាស់?

ហ៊ី ៖ ច្រើនៗ ។

ដារ៉ា ៖ កាលនឹងពូអាច ពូអាចដឹងទេមាន អាចដល់ចំនួនប៉ុន្មានទៅវរសេនាធំ?

ហ៊ី ៖ វរសេនាធំនឹងចង់ពាន់នាក់ដែរនឹង ១ពាន់នាក់ ។

ដារ៉ា ៖ ១ពាន់នាក់ ហើយនៅសល់?

ហ៊ី ៖ ប្រហែលម៉ាកងតូច ។

ដារ៉ា ៖ ម៉ាកងតូចប្រហែលជា?

ហ៊ី ៖ ជា៥០នាក់ទៅ១០០នាក់ ។

ដារ៉ា ៖ ខ្លាំងមែនទែន?

ហ៊ី ៖ ដល់មែនទែន ខ្មោចគរលើគ្នា ដាក់ដឹកជញ្ជូនអត់អស់ ខ្មោចគរលើគ្នា ហើយដល់ខ្ញុំនឹងក៏ត្រូវដែរនឹង ហ្នឹងត្រូវគ្រាប់នៅសិត្ស នៅរហូតដល់សព្វថ្ងៃ ។ ស្លាប់នៅបែកចានបានស្លាប់ខ្លាំងម៉ាវរៈ១១៩ខ្លាំងមែនទែន អស់ទាល់តែកងតូចនេះ ស្លាប់គរលើគ្នាដូចនេះអញ្ចឹងដល់មែនទែនអាគ្រោះបោលបុកខ្លាំងនឹង គេក្រាបជាមួយខ្មោច ហើយត្រង់សេរអត់មានដីកឡើងខ្ពស់ទេ ដីកនៅរាបនឹងដីស្មើ ហ៊ានបើកបន្តិចអាគ្រោះបុកឆ្ងាយអស់ ។

ដារ៉ា ៖ អញ្ចឹងនៅគៀកជាមួយនឹង?

ហ៊ី ៖ គៀកគ្នា ឡើងមកជាមួយថ្នល់ជាតិបាទ! គៀកគ្នាប្រហែលពីថ្នល់ជាតិ ប្រហែលពីនឹង អត់ហ៊ានអើត គ្រាន់អើតក្បាលតិចៗនឹង ។

ដារ៉ា ៖ ហើយដល់ពេលស្លាប់អញ្ចឹងទៅ កូនចៅប្រជាជនមិនដឹងអ្នកណា ជាអ្នកណា ហើយបាត់?

ហ៊ី ៖ បាទ! បាត់ទាំងអស់ ។

ដារ៉ា ៖ ដូចថាបាត់ពត៌មានរកប្រវត្តិរកអីមិនបាន?

ហ៊ី ៖ បាទ! រកប្រវត្តិអត់ឃើញទេ ហើយខ្ញុំនឹងខំមកនឹងគេដែរទេ ខ្ញុំបានរត់ចេញដែលគេឲ្យសែងខ្មោចចេញមកនឹងហើយ ខ្ញុំរត់ចេញមកបណ្តោយ កុំអីដែលបានរត់ អត់បានរស់ទេ សែងខ្មោចចេញមកហើយ ខ្ញុំក៏គៀសខ្លួនរត់មកផ្ទះបណ្តោយមក ។

ដារ៉ា ៖ រត់ពីកន្លែងបែកចាននឹងម៉ង?

ហ៊ី ៖ បាទ! រត់ពីបែកចានភ្នំបាសិត ។

ដារ៉ា ៖ រត់ទៅដល់?

ហ៊ី ៖ ដល់ផ្ទះ ព្រែកស្តី ហើយ៣យប់៣ថ្ងៃបានទៅដល់ ដើរកាត់វាលកាត់ព្រៃទៅ ។

ដារ៉ា ៖ បាទ! កាលរត់នឹង ប៉ុន្មាននាក់ទៅ?

ហ៊ី ៖ ម្នាក់ឯង ខ្ញុំហ៊ានរត់ម្នាក់ឯង បបួលអាមួយដែរឲ្យវាមកដែរ វាអត់ហ៊ានមក ថា«អញមិនទៅទេ» «បើឯងមិនទៅកុំមាត់ប្រាប់អ្នកណាថាអញទៅណា» ។ ៣យប់៣ថ្ងៃដើរតែយប់ទេ ថ្ងៃអត់ហ៊ានដើរដេក ខ្លាចគេឃើញ ។

ដារ៉ា ៖ ហើយដល់ពេល?

ហ៊ី ៖ ក៏វិលត្រឡប់ បាទ! ចេញពីធ្វើយោធាមកវិញ ក៏គេចាប់ខ្ញុំបញ្ជូនមកមន្ទីរ១៥នេះណា១ ។

ដារ៉ា ៖ ពេលពូមកដល់កន្លែងផ្ទះនឹង គេចាប់ពីផ្ទះទៅ ឬយ៉ាងម៉េចពូ?

ហ៊ី ៖ គេចាប់ពីផ្ទះនេះ គេមិនចាប់យើងនេះទេគេ ដូចក្នុងសំណុំរឿងមិញអញ្ចឹង គេបានថាឃើញឈ្មោះយើងនឹងហើយ បានគេបញ្ជូនឲ្យឈ្មោះនឹងទៅវិញ ចេះបានបញ្ចូលក្នុងមន្ទីរ១៥នឹងគេធ្វើបាបនឹង គេវ៉ៃឡើងសន្លប់ ចង់បែកក្បាលបែកអីនឹង មិនដឹងអីទេ ក៏គេសួរចម្លើយនឹងទៀត ក៏ខ្ញុំឆ្លើយតាមនឹងទៅ ។ ដល់ពេលអាឆ្លើយតាមនឹងទៅ កន្លែងនឹងគេហូបគល់ចេក១ ខ្ញុំក៏អត់ហូប១ពេទ្យថា«ឥឡូវឯងមិនស៊ីនឹងទេ ឥឡូវឯងទៅកន្លែងនោះទៅមានអង្ករមួយគ្រាប់១លាយម្សៅជ្រៃ គេកូរលាយម្សៅ លាយគ្រាប់ពោតខ្លះ គ្រាប់អង្ករខ្លះ ក៏កាត់ឲ្យយើងម៉ាត្រុំម្នាក់ ។ ដល់ចេញពីនឹងទៀត មកជាប់នឹងតាខ្មៅ១មួយទៀត ថា«ឯងចេញពីនឹងទៅ១តាខ្មៅនោះបានបាយស៊ី» ទៅដល់នោះគេចែកបាយម៉ាចាន១ ប៉ុនដាក់គុកទាំងយប់ទាំងថ្ងៃនឹង ដាក់ខ្នោះជើងនឹង ។ ដល់រយៈបានម៉ាខែជាងម៉ាខែគេហៅទៅសួរចម្លើយ នៅគុកទួលស្លែងទៀត ។

ដារ៉ា ៖ អញ្ចឹងពេលដែលពូទៅដល់កន្លែងភូមិអ្នកភូមិរដ្ឋអំណាចភូមិឃុំនឹងគេបញ្ជូន ឬក៏មានអ្នកតាម?

ហ៊ី ៖ មានពីប្រធានមន្ទីរនេះ ប្រធានមន្ទីរពីលើនេះទៅ ប្រធានពីលើទៅគេស៊ើបសួរដឹងថាយើងនៅផ្ទះហើយណា ក៏គេមកបញ្ចុះបញ្ចូលគេថានៅកន្លែងនោះ ឲ្យឯងទៅវិញទៅ គេអត់ធ្វើអីទេវាចេះណា ។

ដារ៉ា ៖ មកពីកន្លែងកងទាហាន?

ហ៊ី ៖ បាទ១ ។

ដារ៉ា ៖ ដែលពូធ្លាប់ធ្វើការនឹង?

ហ៊ី ៖ បាទ១ ។

ដារ៉ា ៖ មកដល់កន្លែងភូមិទៅ ខាងទាហានគេស៊ើបមកដឹងថាពូមកដល់ភូមិ ដល់អញ្ចឹងទៅគេបញ្ជូន?

ហ៊ី ៖ ហ្នឹងគេបញ្ជូន ខ្ញុំឡើងទៅវិញ យកបញ្ជូននៅកន្លែងមន្ទីរ១៥នឹងបណ្តោយ ។

ដារ៉ា : កាលមុនដំបូងមិនមែនប្រាប់ថាទៅមន្ទីរ១៥ទេ?

ហ៊ា : បាទ! អត់ទេ ថាយកមកឲ្យធ្វើការ មេគាត់មានថាអីទេបេះណា ដល់មកដល់នឹង ក៏គេបញ្ជូនខ្ញុំមកមន្ទីរ១៥បណ្ដោយមក ។

ដារ៉ា : កាលពូមកកន្លែងភូមិព្រែកស្ដី ពូកាលនឹងភ្នំពេញបែកនៅ ខ្មែរក្រហមវ៉ៃបានភ្នំពេញអត់?

ហ៊ា : នៅ មិនទាន់បែកទេ ។

ដារ៉ា : អញ្ចឹងមានតែក្រោយ៧៥ទេ?

ហ៊ា : បាទ! ក្រោយ៧៥ ។

ដារ៉ា : អឺ! មិនមែនទេ មុន៧៥?

ហ៊ា : មុនៗ៧៥ មិនទាន់បែកទេ ចុះនៅសិក្សានៅអីកាលនៅធ្វើ ។

ដារ៉ា : អញ្ចឹងមានន័យថានៅកន្លែងព្រែកស្ដីនឹង ខាងខ្មែរក្រហមកាន់កាប់ហើយអញ្ចឹង?

ហ៊ា : កាន់កាប់ហើយអស់ហើយនឹង កាន់កាប់ទាំងអស់ អត់តែភ្នំពេញនឹងទេ ។

ដារ៉ា : អញ្ចឹងជំនៀរនឹងខ្មែរក្រហម?

ហ៊ា : បាទ!ខ្មែរក្រហមទាំងអស់ ។

ដារ៉ា : អញ្ចឹងពេលមកដល់កន្លែងព្រែកស្ដីនឹង ក៏ប្រាប់ឲ្យថាទៅធ្វើការវិញ គេអត់យកទោសពៃរ៍អីទេ?

ហ៊ា : គេអត់យកទោសពៃរ៍អីទេ ក៏ខ្ញុំវិលត្រឡប់ទៅវិញនឹង ក៏គេយកបញ្ជូនទៅមន្ទីរ១៥នឹងបណ្ដោយ ។

ដារ៉ា : ខ្ញុំចង់សុំសួរមន្ទីរ១៥នឹងតិច មន្ទីរ១៥នឹង ជាមន្ទីរអីពូ?

ហ៊ា : មន្ទីរស្រុកតំបន់គេ នៅតាមឧបមាថាខេត្តបន្ទាយមានជ័យអញ្ចឹង មានគុកមួយអញ្ចឹង បាទ! អានឹងគុកធំអី មិនធំទេ គុកនៅតាមខេត្ត ដល់គុកទួលស្លែងយើងបានគុកធំបណ្ដោយមិនអញ្ចឹង ។

ដារ៉ា : ចុះមន្ទីរ១៥នឹង ដែលពូហៅថាមន្ទីរនឹង តាមពិតជាមន្ទីរ ឬក៏ជាគុកកាលនឹង?

ហ៊ា : គុក បាទ!គេដាក់មន្ទីរ១៥នឹងបណ្ដោយ ។

ដារ៉ា : ហើយកាលនឹងអ្នកណាគ្រប់គ្រងកន្លែងមន្ទីរ១៥នឹង?

ហ៊ា : អត់បានស្គាល់ដែរ បាទ! អត់ដែលស្គាល់ ។

ដារ៉ា : អញ្ចឹងពេលខ្ញុំអានឯកសារមិញ ថាឈ្មោះគេងនឹងគឺ?

ហ៊ា : គេងនឹងធ្វើប្រធាន ។

ដារ៉ា ៖ ប្រធានអី?

ហ៊ា ៖ អាប្រធានអាកន្លែងធ្វើឆ្នាំង ធ្វើចាន ។

ដានី ៖ ចុះឈ្មោះស្នង?

ហ៊ា ៖ ស្នងនឹង វរៈ១១៩ដែរ ប្រធានវរៈ១១៩នឹង ។

ដារ៉ា ៖ អញ្ចឹងពូអត់ដឹងថាអ្នកណាគ្រប់គ្រងកន្លែង?

ហ៊ា ៖ មន្ទីរ១៥នឹងអត់បានដឹង ។

ដារ៉ា ៖ ហើយបន្ទាប់ពីមន្ទីរ១៥នឹង បេញបន្តទៅទៀតបញ្ជូនមក?

ហ៊ា ៖ មកនៅតាខ្មៅ ។

ដារ៉ា ៖ ទៅនៅតាខ្មៅ ជាមន្ទីរជាអី?

ហ៊ា ៖ អានឹងមក ឧបមាគេមកពីស្រុកដល់ខេត្តម៉ាខេត្តបានឡើងដល់គុកទួលស្លែង គុកធំបណ្តោយវាចេះ ។

ដារ៉ា ៖ នៅប្រហែលជារយៈប៉ុន្មានបានបញ្ជូនចេញពីមន្ទីរ១៥នឹង?

ហ៊ា ៖ នៅប្រហែលមួយខែជាង ពីរខែនោះ ។

ដារ៉ា ៖ កាលនឹងពូនៅចាំថាខែប៉ុន្មាន?

ហ៊ា ៖ អត់បានចាំ វាយូរពេកហើយ ។

ដារ៉ា ៖ កាលរត់មកផ្ទះនឹង ប្រហែលជា?

ហ៊ា ៖ អត់បានចាំដែរ ។

ដារ៉ា ៖ អញ្ចឹងរត់មកផ្ទះបានប៉ុន្មានថ្ងៃ?

ហ៊ា ៖ ទើបបានតិច បានប្រហែល៦-៧-៨ ថា១០ថ្ងៃចុះយ៉ាងលឿន មកដល់ប្រហែលរយៈតិចពេកនោះ ។

ដារ៉ា ៖ ហើយបានជួបជាមួយឪពុកម្តាយអីដែរ?

ហ៊ា ៖ ជួប បាទ!ជួប ។

ដារ៉ា ៖ ហើយបានរៀបរាប់អីខ្លះប្រាប់ឪពុកម្តាយ?

ហ៊ា ៖ ប្រាប់គាត់វាអញ្ចឹងទៅ គាត់មិនដឹងថាម៉េច មនុស្សពិបាកពេក គាត់ដូចថាស្រណោះកូនមិនចង់ឲ្យបែកទៅ ប៉ុន្តែមិនដឹងធ្វើម៉េច ព្រោះគេទៅអញ្ចឹងហើយណា ។

ដារ៉ា ៖ អញ្ចឹងពូអត់ច្បាស់ទេថា រយៈពេលប៉ុន្មាន បានបញ្ជូនពីមន្ទីរ១៥ទៅតាខ្មៅ?

ហ៊ា ៖ បាទ! ប្រហែលជាង១ខែប៉ុននឹងឯង ប្រហែលជាងម៉ាខែ ។

ដារ៉ា ៖ ហើយទៅដល់គាខ្មៅនឹង រយៈពេលប៉ុន្មាន បានបញ្ជូនគេទៀត?

ហ៊ា ៖ ដាក់ប្រហែលម៉ាខែទៀត បានគេបញ្ជូន គេសួរចម្លើយពីនឹងហើយប្រហែលម៉ាខែនឹង បានគេបញ្ជូនទៅទួលស្លែង ។

ដារ៉ា ៖ ពូអាចរៀបពីកន្លែងគាខ្មៅ ពូថាជួបប្រទះរឿងរ៉ាវអីខ្លះ ហើយគេធ្វើបាបអីយ៉ាងម៉េច ពូអាចរៀបរាប់?

ហ៊ា ៖ អានឹងគេសួរចម្លើយយើង ហើយគេវ៉ៃគេដំយើងអញ្ចឹង វ៉ៃដំហើយតាំងពីកាលលំបាកវេទនាថាជាប់គុកនឹងវាហួសនិស្ស័យនិយាយហើយ វាលំបាកតាំងពីហូបដេកចុកបុកទំពារឡើងមួយចប់ ហើយនឹងវ៉ៃដំសួរចម្លើយយើងនឹង ក៏ខ្ញុំគ្មានពាក្យពេចន៍នឹងឆ្លើយនឹងគេ ក៏ខ្ញុំឆ្លើយថា "ជីវិតខ្ញុំមានតែប្រគល់ជូនបងឯង បងឯងចង់សម្លាប់ក៏សម្លាប់ចុះ ខ្ញុំមិនអាចកែប្រែបាន" ។

ដារ៉ា ៖ ហើយកាលនៅមន្ទីរគាខ្មៅនឹង មានអ្នកណាសួរចម្លើយពូ?

ហ៊ា ៖ អត់បានដឹងនេះដែរ ពូថាប្រធានៗមន្ទីរនឹងអ្នកសួរចម្លើយខាងគុកនឹងដែរ អត់សួរចាំឈ្មោះគេដែរទេ ក៏គេបញ្ជូននឹងវិញ គេសួរបញ្ជាក់យកបញ្ជូនខ្ញុំឡើងទៅទួលស្លែងម្តងទៀត ទៅនោះវិញ ។ ដល់នោះទៀត ក៏ខ្ញុំចុះដំបៅគ្រាបៀរឡើងអស់ហើយជើង ដាក់ខ្នោះស៊ីដល់ឆ្អឹងហើយអស់ហើយក៏ដើរលេងទៅណាមកណារួច ក៏គេប្រលែងៗក្នុងទ្រុងៗដាក់ទ្រុងដែកនឹង ។ អាកន្លែងគុកដុះថ្មចេញៗដាក់គុកមួយៗចេះ ម៉ាចំហរចេះ គេប្រលែងអ្នកដើរអត់រួច ហើយនឹងស្គម ។ ក៏គេប្រហែលម៉ោង១២យប់ គេហៅខ្ញុំសួរចម្លើយទៀត ក៏សួរអញ្ចឹងក៏ខ្ញុំឆ្លើយអញ្ចឹងទៀត គេថា"ឯងមិនខ្លាចគ្គគោខែ្សភ្លើង" ខ្ញុំថា"វាខ្លាចនោះខ្លាច ប៉ុន្តែជីវិតខ្ញុំជូនបងឯងខ្ញុំអត់មានពាក្យពេចន៍ឆ្លើយហួសពីនឹងទេ បើបងឯងចង់សម្លាប់ខ្ញុំក៏សម្លាប់ទៅចុះ" វាចេះបានគេបញ្ចេញខ្ញុំពីគុកទួលស្លែងមកវិញ ។

ដារ៉ា ៖ ពីគាខ្មៅ?

ហ៊ា ៖ ហ្នឹងឡើងពីគាខ្មៅទៅដល់គុកទួលស្លែង ។

ដារ៉ា ៖ មិញខ្ញុំកំពុងសួរលោកពូនៅកន្លែងគាខ្មៅ?

ហ៊ា ៖ បាទៗ ។

ដារ៉ា ៖ នៅកន្លែងគាខ្មៅនឹង ពួកខ្មែរក្រហមសួរចម្លើយប៉ុន្មានដងអី ពូចាំទេ?

ហ៊ា ៖ អូ! ៦-៧ដងនោះ ញឹកណាស់ សឹងរាល់យប់ សួរយើងមិនមែនបាន១០ថ្ងៃ កន្លះខែសួរយើងម្តងទេ សួរយើងសឹងរាល់យប់ ។

ដារ៉ា ៖ ហើយជាទូទៅច្រើនតែហៅទៅសួរពេលណា?

ហ៊ៈ ពេលយប់ ។

ដារ៉ាៈ ពេលយប់?

ហ៊ៈ បាទ!យប់ប្រហែលម៉ោង៩ ម៉ោង១០ ។

ដារ៉ាៈ ហើយម៉េចអញ្ចឹងបានហៅតែយប់?

ហ៊ៈ មិនដឹងម៉េចវា យប់ឡើងក៏ឮសូរមាត់ស្រែករញ៉េរញ៉ៃ គេវ៉ៃនោះឮសូរដាក់មន្ទីរនឹង គេហៅសួរចម្លើយក៏ឮសូរមាត់ស្រែក ។

ដារ៉ាៈ ហើយក្រោយមក ពូមានដឹងថាកន្លែងតាខ្មៅវានៅម្តុំណាអី ជាអគារក្បែរកន្លែងណាទេ ពូស្គាល់ទេ?

ហ៊ៈ អាមកក្រោយនេះហើយនឹង ។

ដារ៉ាៈ កន្លែងតាខ្មៅ?

ហ៊ៈ តាខ្មៅនឹង ខ្ញុំចាំបានដែរនឹង វាហួសមើលមកដូចផុតពីម៉ាស្ពានយើងដឹងអីកន្លែងណាទេ ចង់ភ្លេចដែរនឹង ប៉ុនចាំមានស្រះទឹកមួយនៅតាខ្មៅ ផ្ទះថ្មកាលពី៧៩ខ្ញុំខស្សាហ៍ទៅដែរ ថាកន្លែងនេះជាប់គុក កន្លែងនឹង ឥឡូវខ្ញុំចង់វង្វេងចង់ភ័ន្តភាំងអស់ដែរនឹង ។ កាលពី៧៩ ខ្ញុំនៅចាំដែរ ខ្ញុំឡើងទៅភ្នំពេញនឹង ខ្ញុំទៅចង់អន្ទុលប្រាប់អ្នកស្គាល់ៗថាកន្លែងនេះ អញជាប់កន្លែងនេះ ។ ហើយគេដូចថាគេ តាកាតដែលជាមេធំរបស់ខ្ញុំទៀតនឹង ។

ដារ៉ាៈ តាអី?

ហ៊ៈ តាកាត តាសុខកាលនៅតំបន់នឹង តាកាត តាសុខប្រធានតំបន់ៗនឹង តំបន់នឹងរបស់គេ ប៉ុន្តែគាត់នឹងធ្វើប្រធានៗនៅម៉ាស្រុកកោះធំនឹង ។ គេចាប់គាត់ហើយ បានចាប់ខ្ញុំទៀត ហើយគេក៏សួរបញ្ហាថា«តើវាឲ្យធ្វើអីខ្លះ?» ចេះណា ហើយខ្ញុំថា«អត់ទេ មានឲ្យធ្វើអី គេឲ្យនៅកន្លែងមានឲ្យទៅស្អីៗណាអត់» ។

ដារ៉ាៈ កាលពីកន្លែងនៅ ជាប់នៅតាខ្មៅនឹង ពូមានសួរចម្លើយអី មានសួរទាក់ទងនឹងកាលប្រយុទ្ធអី ចាញ់ស្លាប់មនុស្សច្រើន បែកចានអី មានសួរពីមូលហេតុអញ្ចឹងទេ?

ហ៊ៈ វាអត់ទេ វាសួរពីយើង ចោទពីយើងរត់ បាទ! វាចោទអញ្ចឹងទេ ។

ដារ៉ាៈ អញ្ចឹងមូលហេតុសំខាន់ដែលសង្កត់ធ្ងន់នៅពេលដែលសួរចម្លើយនោះ គឺទាក់ទងពីរឿងរត់?

ហ៊ៈ បាទ!

ដារ៉ាៈ ហើយកាលនឹងពូឆ្លើយថាម៉េចទាក់ទងនឹងរត់?

ហ៊ី : រត់ខ្ញុំប្រាប់ត្រង់ថាខ្ញុំខ្លាចៗគេបានខ្ញុំរត់ វាចេះខ្ញុំឆ្លើយត្រង់បណ្ដោយ ខ្ញុំខ្លាចខ្ញុំឆ្លើយប្រាប់ថា "ខ្ញុំរត់" វាទាល់តែរិះដៃអ្នកសួរនឹងណា វាទាល់តែរិះវាគប់ម៉ាកន្ទុយបារី ឲ្យអាដោះគោកំប៉ុង នោះវាឲ្យស៊ី វាចេះ ថា"ឯងរឹងណាស់" ដោយខ្ញុំម៉េចមិនខ្លាច បានខ្ញុំរត់នឹង បើខ្ញុំមិនខ្លាចអត់រត់ ។

ដារ៉ា : អញ្ចឹងពេលដែលជាប់នៅតាខ្មៅប្រហែលជាងម៉ាខែនឹង ហើយពូធ្វើម៉េចបានគេបញ្ជូនទៅណាទៅណែទៀត?

ហ៊ី : បានគេនៅតាខ្មៅនឹងហើយ បានគេបញ្ចេញទៅគុកទួលស្លែង ។

ដារ៉ា : បញ្ចេញនៅពេលថ្ងៃ ពេលយប់?

ហ៊ី : ពេលយប់ ដាក់ឡានទៅ ។

ដារ៉ា : ដាក់ឡានៗម៉ាក់អី?

ហ៊ី : អាឡានអាពួកអាហ្សីប ។

ដារ៉ា : អាហ្សីប?

ហ៊ី : ទាហាន ឡានទាហានអាហ្សីប ។

ដារ៉ា : បាទ! ឡានទាហានដូចរបៀបរបស់ចិនអីនឹង?

ហ៊ី : បាទៗ អានឹងបញ្ជូនទៅដាក់ទៅទួលស្លែង បានចេញពីទួលស្លែង សួរចម្លើយចេញមកវិញបានគេបញ្ចេញមកតាខ្មៅវិញ ។ បាទ!មកតាខ្មៅវិញនឹង គេឲ្យយើងធ្វើការឲ្យធ្វើការរួចហើយ ពេលយប់ឡើងគេដាក់គុក ថ្ងៃឡើងគេមានអ្នកយាមយើងដើរបណ្ដើរទៅធ្វើការនឹង ។

ដារ៉ា : អញ្ចឹងសុំលោកពូជួយរៀបរាប់ពីកន្លែងតាខ្មៅមកទួលស្លែងនឹងទៅ មកដល់ភ្លាមទៅពូជួបអ្នកណាឃើញយ៉ាងម៉េច ហើយគេសួរអី សួរចម្លើយម៉េចពូ?

ហ៊ី : ពីអត់មានបានសួរអីណាយើងនេះទេ គេហៅពេលដែលយើងសួរចម្លើយយើង ។

ដារ៉ា : ហៅយកពីតាខ្មៅមកទួលស្លែងនឹង ពេលយប់អញ្ចឹង?

ហ៊ី : បាទៗ ពេលយប់ ។

ដារ៉ា : ពេលយប់មកដល់ភ្លាមដំបូងនឹង សួរភ្លាមឬយ៉ាងម៉េច?

ហ៊ី : គេទុកយើងម៉ាយប់សិន ទុកយើងម៉ាយប់ហើយបានគេសួរចម្លើយយើង ។

ដារ៉ា : ទុកនឹង ទុកនៅកន្លែងអគារណា ពូចាំទេ?

ហ៊ី : អឺ!មិនសូវចាំដែរនឹង ចាំបានតែកន្លែងនឹង អានឹងនៅខាងជើងវាំង ។

ដានី : ទួលស្លែង?

ហ៊ិ : បាទ! ពុទ្ធនឹង ទួលស្លែងនៅនឹង ឬនៅណា ដូចវង្វេងហើយ មានទ្រង់ដូចទ្រង់គេដាក់អីអញ្ចឹង វ៉ែស្ទុតែដែកខ្នោះទាំងអស់អញ្ចឹង គេប្រលែងចូលក្នុងនឹង គេដាក់ជាប់ក្នុងនឹងដែរ ។

ដារ៉ា : ចុះហេតុអីបានពូដឹងថាកន្លែងនឹងជាទួលស្លែង?

ហ៊ិ : អើយ!គេប្រាប់ មេប្រាប់គុកកន្លែងគុកទួលស្លែង ។

ដារ៉ា : ដែលយកពីតាខ្មៅមកនឹង?

ហ៊ិ : បាទៗ មកគុកទួលស្លែង ។

ដារ៉ា : ហើយកាលយកជិះឡានជិះអីមានជាសន្តិសុខមានអីមក ម៉ូតូដឹកឡានអីយ៉ាងម៉េចៗ?

ហ៊ិ : អត់មានទេ ។

ដារ៉ា : ដឹកឡានទៅយ៉ាងម៉េច?

ហ៊ិ : អត់ទេ មានតែទាហានម្នាក់២នាក់ជិះក្នុងឡានមកជាមួយយើង ។

ដារ៉ា : ហើយមកជិះឡាននឹង ជាប់ទាំងចំណងឬក៏?

ហ៊ិ : ដាក់ខ្នោះដៃ ។

ដារ៉ា : ជើងអត់ទេ?

ហ៊ិ : ជើងគេប្រលែងដាក់តែឃ្នោះដៃទេ ។

ដារ៉ា : ហើយឡាននឹងដាក់ឃ្លុប ឬក៏យើងអាចមើលឃើញចេញទៅក្រៅ?

ហ៊ិ : វាបាំងក្រណាត់ចេះ បាំងជិតក្រណាត់ ។

ដារ៉ា : បាំងទ្រង់ចេះម៉ង?

ហ៊ិ : បាទៗ ។

ដារ៉ា : ប៉ុន្តែ បើសិនជាមើលទៅក្រោយ មើលឃើញទេ?

ហ៊ិ : មើលក្រោយក៏វាអត់ឃើញ បើវាបាំងជិតទាំងអស់ ។

ដារ៉ា : វាឃ្លុបម៉ង?

ហ៊ិ : បាទៗ វាឃ្លុប ។

ដារ៉ា : អូ! យប់?

ហ៊ិ : បាទ! យប់ ។

ដារ៉ា : អញ្ចឹងចុះមកដល់ភ្នាម ពូគិតថាកន្លែងនឹងទួលស្លែងម៉ង ឬយ៉ាងម៉េច?

ហ៊ា ៖ បាទ! ទួលស្លែង សួរអ្នកជាប់ៗគុកជាមួយគ្នានឹង ហើយយើងយកមកដល់ភ្លាមវាប្រលែងដាក់នៅជាមួយគ្នានឹង សួរថា«កន្លែងនឹងហៅកន្លែងអី» គេហៅថា«អានឹងគុកទួលស្លែង» ហ្នឹងអ្នកជាប់មុនខ្ញុំ ។

ដារ៉ា ៖ ដឹងដែរ ដឹងថាកន្លែងនឹងជាគុកទួលស្លែងអញ្ចឹង?

ហ៊ា ៖ បាទ!

ដារ៉ា ៖ ឬក៏អ្នកជាប់មុនគេប្រាប់?

ហ៊ា ៖ អ្នកជាប់មុនគេប្រាប់ ។

ដារ៉ា ៖ មិនប្រាប់ថាទួលស្លែង តែបែរជាប្រាប់ថាជាមន្ទីរស្អីមួយកាលជំនាន់ខ្មែរក្រហមគេប្រើយ៉ាងម៉េច?

ហ៊ា ៖ អត់ទេ អានឹងគេប្រាប់ថាគុកទួលស្លែងនឹងម៉ង តាំងពីទាហានសក្ដិ៥ សក្ដិ៣ សក្ដិ២អ្នកអីណានោះ ដាក់នៅនឹងនេះ ដល់លុះគ្រាតែអ្នកឯងដើររួចបានគេប្រលែង ដើរនៅដើររួចគេដាក់ឃ្នោះយើង ។

ដារ៉ា ៖ អញ្ចឹងពេលពូមកដល់កន្លែងទួលស្លែងដំបូងនឹង គេទុកនៅក្នុងទ្រង់នឹង ប៉ុន្តែនៅជាប់ខ្នោះនៅឡើយ?

ហ៊ា ៖ បាទ! នៅជាប់ខ្នោះនៅឡើយ ។

ដារ៉ា ៖ កាលនឹងពេលមកដាក់ចូលដល់ទួលស្លែងនឹង មានឆ្មាំគុកមកពីនិត្យអីយ៉ាងម៉េច កត់ឈ្មោះចេញចូលយ៉ាងម៉េចទេ?

ហ៊ា ៖ មានៗ កត់យើងចេញចូល ។

ដារ៉ា ៖ កត់ចេញចូលម៉េច បើយប់?

ហ៊ា ៖ បាទ! យប់នឹង គេយាមនៅក្រៅៗបើកាលណាពូសួរអី ប៉ុន្តែវាដឹងចំនួនទាំងអស់ហើយ ប៉ុន្តែវាយាមក្នុងសងខាងនឹង នៅក្រៅនឹង ដល់ម៉េចៗវាហៅយើងទៅមួយម្ដងៗទៅ ។

ដារ៉ា ៖ អញ្ចឹងពូនៅកន្លែងទ្រង់នឹងម៉ាយប់សិនហើយ?

ហ៊ា ៖ បាទ! ស្អែកឡើងវាហៅខ្ញុំទៅ ប្រហែលម៉ោង១២យប់ បានហៅទៅសួរចម្លើយ ។

ដារ៉ា ៖ ម៉ោង១២យប់រំលងមួយថ្ងៃទៀត បានហៅទៅ មិនមែនហៅពេលថ្ងៃទេ?

ហ៊ា ៖ មិនមែនហៅពេលថ្ងៃទេ ហៅពេលយប់ ។

ដារ៉ា ៖ ពេលមកហៅ ខ្មែរក្រហមប្រាប់ឲ្យហៅរបៀបម៉េច?

ហ៊ា ៖ ដល់ទៅហៅឈ្មោះយើងទៅ យើងចេញទៅដាក់ឈ្មោះដៃឲ្យយើងទៅ ។

ដារ៉ា ៖ ពេលទៅនឹង មានបាំងមុខ បាំងអីអត់ទេ?

ហ៊ី ៖ គេអត់ទេ អត់មានបាំងមុខទេ អត់បង់មុខទេ ។

ដារ៉ា ៖ អញ្ចឹងកាលនឹង ដែលពេលមកដល់កន្លែងទួលស្លែងមិនទាន់បែកទេពូ?

ហ៊ី ៖ នៅ មិនទាន់បែកទេ ។

ដារ៉ា ៖ អត់ទាន់បែកភ្នំពេញទេ?

ហ៊ី ៖ នៅទេ ហ៉េ!ភ្នំពេញបែកហើយ ។

ដារ៉ា ៖ បែកហើយ?

ហ៊ី ៖ បាទ! បែកហើយ ។

ដារ៉ា ៖ បែកហើយបានយកពីតាខ្មៅ មកកន្លែងទួលស្លែង?

ហ៊ី ៖ បែកហើយ ។

ដារ៉ា ៖ ពេលមកដល់ទួលស្លែងនឹង ពូមានស្គាល់សន្តិសុខ ស្គាល់ឈ្មោះអី ពុកគេហៅអី?

ហ៊ី ៖ អត់ស្គាល់ទេក្មួយ ។

ដារ៉ា ៖ ហើយពេលហៅទៅសួរចម្លើយនឹង ឆ្ងាយពីកន្លែងទ្រង់នឹងទេ?

ហ៊ី ៖ វាកន្លែង អត់សូវឆ្ងាយប៉ុន្មានដែរ វាធ្វើជាប់ៗគ្នា កន្លែងខបមាថាវាផ្ទះនឹង ខបមាថាវាមិនឆ្ងាយ វាជិតៗគ្នាដែរនឹង ។

ដារ៉ា ៖ ហើយសួរប៉ុន្មាន អីប៉ុន្មានដង?

ហ៊ី ៖ សួរខ្ញុំនៅនឹង៣ដង ។

ដារ៉ា ៖ ៣ដងគត់ម៉ែង?

ហ៊ី ៖ បាទ! ៣ដងគត់ទេ កន្លែងគុកទួលស្លែងនឹង ចាំច្បាស់ ។

ដារ៉ា ៖ ហើយរៀងរាល់ពេលថ្ងៃ ឬពេលយប់ ពេលយកទៅសួរ?

ហ៊ី ៖ សួរតែយប់ៗរាល់ថ្ងៃ អត់មានសួរថ្ងៃ ។

ដារ៉ា ៖ ហើយរំលងប៉ុន្មានថ្ងៃបានហៅទៅសួរ?

ហ៊ី ៖ ប្រហែល៨-១០ថ្ងៃ យកម្តងហៅទៅសួរ ។

ដារ៉ា ៖ ហើយកាលទៅសួរនឹង សង្កត់អីធ្ងន់ជាងគេ ងារឿងសួរ?

ហ៊ី ៖ សង្កត់ពីខ្ញុំដើរបំផុសបំផុល ហើយនឹងគេបញ្ជាឲ្យខ្ញុំធ្វើអីខ្លះ បានធ្វើអញ្ចឹង ។

ដារ៉ា ៖ អញ្ចឹង?

ហ៊ី ៖ បាទ! ថាគ្មានបញ្ហាអ្វីទេ គ្មានអ្នកបញ្ហាឲ្យខ្ញុំធ្វើអ្វីទេ ប៉ុន្តែគ្រាន់តែខ្ញុំខ្លាចដែលវ៉ៃទៅវាងាប់ច្រើនពេក ខ្ញុំរត់បណ្តោយទៅ អានេះវាចេះ ។

ដារ៉ា ៖ ហើយមានសួរទាក់ទងនឹងដូចថាជាប់ពាក់ព័ន្ធជាមួយមនុស្សណាៗគទៅទៀត ជាអ្នកដែលធ្វើការលោកពួនឹង មានសួរទាក់ទងនឹងបញ្ហានឹង?

ហ៊ី ៖ វាសួរថាគ្រាន់ថាដូចមេប្រធានមន្ទីរអញ្ចឹង វាប្រាប់ថា«វាឲ្យឯងធ្វើអីខ្លះចេះ» ខ្ញុំថា«អត់ឲ្យធ្វើអី ឲ្យខ្ញុំនៅចាំមន្ទីរនឹង នៅទៅគ្រាន់គេនៅធ្វើអីៗខ្ញុំអត់ដឹង» ។

ដារ៉ា ៖ អញ្ចឹងសួរពាដងអញ្ចឹងពូជាប់ប្រហែលជារយៈពេលប៉ុន្មាន?

ហ៊ី ៖ ប្រហែលម៉ាខែលើសតិចទេ នៅទួលស្លែងនឹងប៉ុននឹងទេ បានវាបញ្ចេញមកវិញ មកតាខ្មៅនឹង ។

ដារ៉ា ៖ អញ្ចឹងកាលពូជាប់នៅទួលស្លែងនឹង ស្គាល់អ្នកណាជាប្រធានគុកទួលស្លែងច្បាស់លាស់នឹងនៅពេលណា?

ហ៊ី ៖ អត់បានច្បាស់លាស់ទេ សូម្បីតែនិយាយអន្ទុយនិយាយជាមួយគ្នា វាអត់ឲ្យនិយាយទេ តែហ៊ាននិយាយវាវ៉ៃ ។ និយាយទៅជាប់គុកដាក់ម៉ាអណុងវែងអញ្ចឹងឲ្យនៅអញ្ចឹងបណ្តោយទៅអត់ឲ្យ ។

ដារ៉ា ៖ ម៉ាអាណុងវែងអញ្ចឹងមានអ្នកទោសច្រើនទេ?

ហ៊ី ៖ បាទ! អ្នកទោសតែ១០នាក់ទៅ១៥នាក់ម៉ាអាណុងៗវា វាដាក់តាមវែងនឹង ម៉ាអាណុងនឹងឲ្យតែពួសួរនិយាយគ្នា ពួសួរតែដែកម៉ាក្រឹមវាមកវ៉ៃ ។

ដារ៉ា ៖ អញ្ចឹងពេលដែលជាប់នៅកន្លែងទួលស្លែងនឹងហើយ បញ្ជូនមក?

ហ៊ី ៖ ទោសយើងវាអស់ៗទោសណា ដល់កន្លែងនឹងវាអស់សួរកន្លែងនឹងវាចប់ហើយ បានបញ្ជូនមកកន្លែងនឹងវិញ ។

ដារ៉ា ៖ មកតាខ្មៅនឹងវិញ?

ហ៊ី ៖ បាទ! រៀងស្រាលតិចវិញ ព្រោះថាវាអត់មានដាក់គុកយើងទាំងយប់ទាំងថ្ងៃ ប៉ុន្តែពេលថ្ងៃប្រលែងឲ្យធ្វើការ ពេលយប់ឡើងដាក់ខ្នោះវិញ ថ្ងៃឡើងឲ្យធ្វើការទៅ ជីកកាប់គាស់អីញ្ចឹងទៅណា ។

ដារ៉ា ៖ អញ្ចឹងនៅកន្លែងទួលស្លែង ពូអត់ដឹងថានៅកន្លែងថ្ងៃខែឆ្នាំណាដែលទៅដល់ទេនោះ ប៉ុន្តែពូប្រាកដថាបែកភ្នំពេញហើយ?

ហ៊ី ៖ ហឺ! បែកយូរដែរ បែកយូរហើយ ។

ដារ៉ា ៖ ប្រហែលជាប៉ុន្មាន បែកភ្នំពេញរយៈពេលប៉ុន្មាន?

ហ៊ា ៖ បែកចន់ម៉ាឆ្នាំដែរនឹង ។

ដារ៉ា ៖ ចន់ម៉ាឆ្នាំដែរហើយ បានគេបញ្ជូនមក?

ហ៊ា ៖ បាទៗ ។

ដារ៉ា ៖ ហើយពេលបញ្ជូនត្រឡប់ទៅវិញនៅតាខ្មៅនឹង ឲ្យធ្វើការងារ?

ហ៊ា ៖ កាប់គាស់រែកពន្លដីកនេះដីកនោះ វាប្រលែងពេលថ្ងៃឲ្យយើងធ្វើការ ហើយគេនៅដើរយាម យើងអញ្ចឹងទៅ ។

ដារ៉ា ៖ តែការងារពេលថ្ងៃទេ?

ហ៊ា ៖ បាទ! ធ្វើពេលថ្ងៃ ។

ដារ៉ា ៖ តែបញ្ជូនទៅតាខ្មៅនឹង គឺកន្លែងដដែលឬម៉េច?

ហ៊ា ៖ បាទ! កន្លែងដដែល ទៅកន្លែងវាដដែល ហើយក៏បញ្ជូនមកនេះ ព្រែកហូរ ព្រែកអាទាំងនេះ ឲ្យមកជីកប្រឡាយទាំងយប់ទាំងថ្ងៃនឹង ដាច់ចិត្តខ្លាំងពេកក៏រត់មកម៉ាសារទៀត មកដល់ផ្ទះហើយកុំអីមានបានរស់អី នៅជាប់គុកខ្ញុំនៅរត់ទៀត ។ ជាប់យើង ប្រលែងវាប្រលែង តែ.....នៅតាខ្មៅនឹង គេប្រលែងធ្វើការប៉ុណ្ណា បើចេញមកនៅមកព្រែកហូរ ព្រែកអាទាំង គេអត់មានដាក់ច្រវ៉ាក់ដៃយើងទេ គេឲ្យយើងជីកប្រឡាយជីកអី រែកដីរែកអីនឹង ដល់ពេល ហូបមិនគ្រប់គ្រាន់នឹងដំបៅដំបៀរអីឈឺស្គមឡើង ខ្ញុំសម្រេចចិត្តរត់ម្តងទៀត ។ បាទ! គ្នា២ នាក់ប៉ុន្តែបបួលពួកម៉ាក់នោះ ថា«អញអត់ហ៊ានទៅខ្លាចជាប់គុកម្តងទៀតវាចេះ» ខ្ញុំថា«បើ ឯងមិនហ៊ានទៅទុកអញទៅ» ហែលទឹកឆ្លងស្ទឹងព្រែកហូរ ព្រែកអាទាំងមកផ្ទះបណ្តោយ៣យប់ ៣ថ្ងៃបានដល់ផ្ទះ បានមកបានពួកនៅផ្ទះនឹង ។

ដារ៉ា ៖ អញ្ចឹងកាលដែលជាប់គុកនៅទួលស្លែងនឹង ប្រហែលជារយៈពេលម៉ាខែជាងទេ?

ហ៊ា ៖ អឺ!កន្លែងទួលស្លែងនឹងជាងម៉ាខែទេ ជាប់នៅតាខ្មៅនឹងប្រហែលចូល២ខែ៣ខែជាប់នៅតាខ្មៅ ជាប់អាដំបូងម្តង ។

**ផ្នែក«១»**

ដារ៉ា ៖ ពីតាខ្មៅ ហើយនឹងនៅទួលស្លែងមួយណាធ្វើខ្លាំងជាង?

ហ៊ា ៖ នៅពីគុកពីក្រោមទៅតំបន់១៥នេះបានធ្វើខ្លាំង វ៉ៃឡើងសន្លប់សុទ្ធតែគល់អុស វ៉ៃស្លរចម្លើយ វ៉ៃបែកខ្នង បែកក្បាលៗស្នាមរហូតដល់សព្វថ្ងៃ ហើយដៃម៉ាចំហៀងខ្ញុំលើកអត់ចង់រួច

ដោយសារអី ដោយសារវាវ៉ៃរហូតដូចជាចង់ខុស ដូចអត់នៅសព្វថ្ងៃ ហើយនឹងមកតាខ្មៅ ធន់កណ្ដាលទេ ហើយនឹងគុកទួលស្លែងនឹង បើខ្លាំងជាងគេនៅមន្ទីរ១៥ ។

ដារ៉ា : កាលដែលធ្វើទារុណកម្មខ្លាំងនៅមន្ទីរ១៥ ពូឆ្លើយយ៉ាងម៉េចដែលអាចរួចខ្លួន?

ហ៊ា : ខ្ញុំអត់មានឆ្លើយម៉េច ខ្ញុំឆ្លើយតែប៉ុននឹង ខ្ញុំថាចង់សម្លាប់ខ្ញុំក៏សម្លាប់ទៅ ខ្ញុំជូនហើយ ធ្វើម៉េចធ្វើទៅថាចេះ បានបញ្ជូនឡើងមកលើទៀត ។

ដារ៉ា : អញ្ចឹងពេលមកដល់ទួលស្លែង ពូគេហៅទៅសួរចម្លើយម៉ោងៗមានរយៈពេល?

ហ៊ា : ប្រហែលកន្លះម៉ោងៗប៉ុននឹង ។

ដារ៉ា : មានសួរពីជីវប្រវត្តិ សួរពីប្រវត្តិការងារអីយ៉ាងម៉េចដែរ?

ហ៊ា : សួរដែរ សួរពីប្រវត្តិយើងនៅផ្ទះធ្វើអីៗនឹងណា ហើយយើងមកធ្វើទាហានធ្វើអីបានប៉ុន្មានឆ្នាំ ប៉ុន្មានខែអញ្ចឹងទៅណា ហើយមូលហេតុអីបានអញ្ចឹង ហើយឯងទាក់ទងជាមួយអ្នកណាខ្លះ ជាមួយមេណាវាហៅអាសុខ អាកាតអញ្ចឹងណា ។

ដារ៉ា : ឈ្មោះកាតអញ្ចឹងពូ?

ហ៊ា : តាកាតមួយ តាសុខនៅតំបន់២៥ «វាឲ្យមកធ្វើអីខ្លះ» «ហើយខ្ញុំមានឲ្យមកធ្វើអីឲ្យនៅកន្លែង ខ្ញុំនៅកន្លែង ឲ្យធ្វើអីធ្វើនឹងទៅ» ។

ដារ៉ា : នៅក្នុងការសួរចម្លើយនៅទួលស្លែងដែលពូរៀបរាប់ថា៣ដងនឹង វាមានការធ្វើទារុណកម្ម យ៉ាងម៉េចខ្លះដែរអត់ទេ?

ហ៊ា : អានឹងវាវ៉ៃបានប៉ុន្មានដងមុនដំបូងទេ វ៉ៃនឹងក្ដគោ បាទ!អាថ្ងៃទីដំបូងណា ។ បាទ!ដល់ថ្ងៃ ក្រោយទៀតខ្ញុំសម្រេចចិត្តថា«ស្លាប់ក៏ស្លាប់ចុះ ថាជីវិតខ្ញុំជូនលោកបងឯងៗចង់ធ្វើអីទៀត ធ្វើទៀតក៏មិនថាអីទេ ព្រោះខ្ញុំមានចម្លើយតែប៉ុននឹង បងឯងនៅតែជីកឫសជីកគល់សួរខ្ញុំ បងឯងចាំបាច់ត្រឹមប៉ុននឹង វ៉ៃខ្ញុំឲ្យស្លាប់ទៀតក៏ខ្ញុំមិនដឹងធ្វើម៉េចចេះ» ។

ដារ៉ា : ពូបាននិយាយពាក្យអញ្ចឹងដាក់?

ហ៊ា : បាទ!និយាយដាក់អញ្ចឹង ខ្ញុំថា«ខ្ញុំមានចម្លើយប៉ុននឹង ជីវិតខ្ញុំជូនបងឯង មិនបាច់ហៅខ្ញុំសួរ ច្រើនដងពេក ចង់សម្លាប់ក៏សម្លាប់ចុះ» ខ្ញុំឆ្លើយអញ្ចឹង វាថា«អានេះមាត់រឹងដល់ហើយ អត់ខ្លាចទេ ក្ដគោ ហើយខ្សែភ្លើង» ខ្ញុំថា«ខ្លាចចេះតែខ្លាចហើយ ប៉ុន្តែខ្ញុំមានចម្លើយតែប៉ុននឹង ហើយជីវិតខ្ញុំជូនបងឯង ហើយខ្ញុំសួរខ្ញុំអត់ដឹង ហើយឲ្យខ្ញុំធ្វើម៉េច បងឯងចង់សម្លាប់ខ្ញុំក៏សម្លាប់ទៅ» ក៏វា«អានេះមាត់រឹងណាស់ឯងទៅវិញទៅ» ក៏វាដក់បារីរូបសេក កាលសម័យនឹងវាមានបារីរូបសេក វាគប់នេះឲ្យខ្ញុំជក់ ។

ដារ៉ា ៖ ដល់ពូបានដក់ដែរ?

ហ៊ី ៖ ដក់ វាឲ្យខ្ញុំដក់ហើយ អង្គុយទល់មុខគ្នាពីរនាក់អញ្ចឹង ហើយទឹកដោះគោយើង ទឹកដោះគោកំប៉ុងម៉េវ៉ាំនោះ វាកក់ដុំៗវាថាស៊ីទៅចេះ ។

ដារ៉ា ៖ អានឹងទៅទួលស្លែង?

ហ៊ី ៖ នៅទួលស្លែង ។

ដារ៉ា ៖ ហើយមានស្គាល់ឈ្មោះអ្នកសួរពូទេ?

ហ៊ី ៖ អត់ស្គាល់ទេ ។

ដារ៉ា ៖ វាអត់បានប្រាប់ទេ?

ហ៊ី ៖ បាទ! អត់មានប្រាប់ទេ ។

ដារ៉ា ៖ ហើយកាលសួរនឹងសួរប៉ុន្មាននាក់ ពេលសួរម្តង?

ហ៊ី ៖ តែម្នាក់ៗតទល់នឹងម៉ង វាអត់មានគ្នា៣-៤នាក់តទល់ដូចយើងទេណា ។

ដារ៉ា ៖ ហើយចុះវាកត់ត្រាអីយ៉ាងម៉េចកើតទៅ សួរអញ្ចឹង?

ហ៊ី ៖ កត់ត្រាៗវារបស់មានអី របស់វាមានមួយកំណរ ។

ដារ៉ា ៖ ពេលវាកត់កំណត់ហេតុកំណត់អីម៉េចទៅ បើវាម្នាក់ឯងទៅ?

ហ៊ី ៖ វានិយាយបណ្តើរវាកត់បណ្តើរ វាអត់មានពីរនាក់ដូចថាប្អូនអ្នកកត់អញ្ចឹង ប្អូននេះអ្នកសួរខ្ញុំចេះអត់ទេ បាទ!វាសួរម្នាក់ៗវាៗកត់បណ្តើរនិយាយបណ្តើរ ។

ដារ៉ា ៖ ហើយមានដែលឲ្យលុបវិញថា អូ!ឆ្លើយអញ្ចឹងមិនត្រូវទេ អាចកែពេលពូនិយាយអីទៅអាចកែអីខ្លះ?

ហ៊ី ៖ អត់ទេ អត់មានកែទេ រឿងកត់រហូត វានិយាយវាកត់ ។

ដារ៉ា ៖ អញ្ចឹងពូនិយាយហូរហែលទៅរហូត?

ហ៊ី ៖ ខ្ញុំនិយាយហូរហែល ខ្ញុំគ្មានខ្លាចអីខ្ញុំៗអត់ខ្លាចទេ ។

ដារ៉ា ៖ បើអ្នកសួរនៅទួលស្លែង ចាំកត់រហូត?

ហ៊ី ៖ បាទ!ចាំតែកត់ទៅ ខ្ញុំអត់មានឆ្លើយរអាក់រអួល ឬមួយក៏ខ្លាចចេះចុះខ្ញុំអត់ទេខ្ញុំអត់មានខ្លាច ។

ដារ៉ា ៖ ចុះមានតែពូនិយាយទៅតាមលំដាប់លំដោយរហូត?

ហ៊ី ៖ បាទ! ខ្ញុំនិយាយតាហូរហែលទាំងអស់ តាំងពីខ្ញុំនៅពីផ្ទះម៉េច ចូលទៅធ្វើការកន្លែងណាៗខ្លះអញ្ចឹង ឲ្យឧបមាដូចជារឿងដោះឡានដោះអីអញ្ចឹង មកពីមូលហេតុអីឲ្យខ្ញុំធ្វើការវាឲ្យខ្ញុំទៅដោះអត់កើតខ្ញុំរត់បណ្តោយ ដោះនៅព្រែកប្រា ។

ដាវ៉ា ៖ ដោះឡានរបៀបម៉េច?

ហ៊ី ៖ អាដោះឡានយកមកធ្វើឆ្នាំង ធ្វើចាន ដោះអាគ្រឿងឡានអញ្ចឹង ដោះយកដែកឌីវ៉ា ។

ដាវ៉ា ៖ ទៅជាឡាននឹងខូចឥឡូវ?

ហ៊ី ៖ ឡានខូចហើយនឹង ឡានខូចសម័យនេះនឹង ក៏ឲ្យយើងដោះដោះយកដែកឌីវាយកមកស្លឆ្នាំងស្លអីនឹងចាក់ស្លាបព្រាចាក់អីនឹង ធ្វើមិនបានគ្រាប់ផង បានខ្ញុំរត់នឹង ។

ដាវ៉ា ៖ អញ្ចឹងមុននឹងទៅទាហាននឹង ពូនៅកន្លែងស្លឆ្នាំងស្លអីធ្លាប់រត់មកផ្ទះដែរ?

ហ៊ី ៖ បាទ! ធ្លាប់រត់ ម្តងនឹងដែលទៅនៅព្រែកប្រានឹង ចាប់បញ្ជូនមួយសារទៀតបានបញ្ជូនឲ្យទៅធ្វើជាយោធា ។ បានចេញពីយោធាទៀត បានជាប់គុកនឹងបណ្តោយរហូតមកទល់៧០ប៉ុន ៧៦អី ចុង៧៦នោះ ដែលខ្ញុំរត់ចេញពីគុកនឹងមកដល់ផ្ទះនេះហើយនឹង បានខ្មោចឪពុកខ្មោចអី បងប្អូនថាខ្ញុំស្លាប់បាត់អស់ហើយ ។ ចុះដឹងដំណឹងកាលភ្នំពេញមិនទាន់បែក ប៉ុន្តែគេអ្នកផ្ទះនៅតំបន់២៥នឹង អាកន្លែងមន្ទីរ១៥នឹង អ្នកផ្ទះនៅជាប់ៗគ្នានឹង នៅជិតគ្នានឹងគេឃើញវិទ្យុឡើងសទ្ធប់ក៏គេយកពត៌មានមកប្រាប់ឪពុកខ្ញុំថាវាងាប់បាត់ហើយ គេវៃឡើងងាប់ដាក់អូសទាក់អូស ។

ដាវ៉ា ៖ ចុះពេលដែលបញ្ជូនពីទួលស្លែងទៅតាខ្មៅនឹង ចង់និយាយថាមានមូលហេតុអីបានបញ្ជូនទៅវិញមានជាលិខិតស្នាមជាអីអញ្ចឹងដែរ?

ហ៊ី ៖ អត់មាន នេះគេកត់ក្នុងបញ្ជីអញ្ចឹងប្អូន រួចហើយបែបអានេះតាមកាលខ្ញុំស្មានទេណា បែបទោសយើងអស់ហើយ គេបន្ថយមកកន្លែងស្រាលវិញអញ្ចឹង មកកន្លែងនឹងវិញៗបានវាបញ្ចេញឲ្យយើងធ្វើការបណ្តោយ ។

ដាវ៉ា ៖ ពីទួលស្លែងទៅតាខ្មៅ យកទៅវិញ ថ្ងៃហើយយប់?

ហ៊ី ៖ មកយប់វិញ ។

ដាវ៉ា ៖ យប់ដដែល?

ហ៊ី ៖ បាទ! អត់ឲ្យមកថ្ងៃទេ មកយប់ទេ ។

ដាវ៉ា ៖ ហើយយ៉ាងម៉េច យប់រហូតអញ្ចឹង?

ហ៊ី ៖ មិនដឹងៗរបៀបម៉េចៗ អត់ឲ្យយើងស្គាល់កន្លែងរបៀបម៉េច ។

ដាវ៉ា ៖ យកមកពីតាខ្មៅ សួរចម្លើយក៏យប់?

ហ៊ី ៖ បាទ! ចេញតែយប់ ។

ដាវ៉ា ៖ ចេញមកវិញតែយប់?

ហ៊ី ៖ បាទ! តែយប់ អត់ឲ្យយើងពេលថ្ងៃឲ្យយើងឃើញកន្លែងវាដឹងថាកន្លែងណាៗទេណា អត់ឲ្យយើងដឹងទេ។

ដារ៉ា ៖ ហើយកាលនឹងពូដឹងស្គាល់មេគុកទួលស្លែងអីនឹង?

ហ៊ី ៖ អត់បានស្គាល់ទេ។

ដារ៉ា ៖ អត់សោះ?

ហ៊ី ៖ ព្រោះថា បាទ!អត់បានស្គាល់ទេ។

ដារ៉ា ៖ កាលមកពីតាខ្មៅ មកទួលស្លែង ប្រហែលប៉ុន្មាននាក់ដឹកឡាន ដឹកមក?

ហ៊ី ៖ គ្នាប្រហែល៦-៧នាក់ដែរ ម៉ោទោសស្រាលៗនឹង វាថយមកវិញហើយ ប្រហែល៧នាក់។

ដារ៉ា ៖ ពីតាខ្មៅមកទួលស្លែងនឹង ខ្ញុំចង់សួរពីតាខ្មៅមកទួលស្លែងនឹងប៉ុន្មាននាក់កាលមកនឹង?

ហ៊ី ៖ ប្រហែល៧នាក់។

ដារ៉ា ៖ ហើយមានស្គាល់ឈ្មោះអ្នកណាអត់?

ហ៊ី ៖ អត់ទេ មិនដឹងនៅណាៗខ្លះទេ គេដាក់យើងមក សូម្បីតែនិយាយប្ញមួយក៏ស្អីនឹងក៏គេមិនឲ្យយើងឃើញដែរ អឺ!មិនឲ្យយើងមើលគ្នា។

ដារ៉ា ៖ នៅក្នុងឡាននឹង អត់ឲ្យនិយាយគ្នាទេ?

ហ៊ី ៖ អត់ឲ្យនិយាយទេ។

ដារ៉ា ៖ មានពួកខ្មែរក្រហមអង្គុយក្នុងឡាន?

ហ៊ី ៖ វានៅអង្គុយក្នុងឡាននឹង ទាហានមនុស្សយាមនឹង។

ដារ៉ា ៖ អញ្ចឹងងងឹតឈឹង បើសិនជាយប់ដាក់យួប់ មិនងងឹតឈឹង?

ហ៊ី ៖ បាទ! ងងឹតឈឹង មិនមើលអីឃើញ។

ដារ៉ា ៖ មើលមុខតែអ្នកទោសដូចគ្នា ក៏អត់ឃើញដែរ?

ហ៊ី ៖ បាទ!អត់ឃើញដែរ។

ដារ៉ា ៖ ហើយអត់ទាំងឃើញខ្មែរក្រហមអង្គុយក្នុងនឹងដែរ?

ហ៊ី ៖ បាទ!

ដារ៉ា ៖ អត់ឃើញដែរ?

ហ៊ី ៖ បាទ!

ដារ៉ា ៖ បើវាអត់យាមក៏អត់អី?

ហ៊ៈ បាទ! ព្រោះមិនបានស្គាល់មុខវា ស្គាល់អីវាច្បាស់ណា គ្រាន់ដឹងថាទាហានវាបញ្ជូនមកវិញ ក៏យកមកដល់ភ្ជាម គេដាក់ឈ្មោះយើងទៀត ។ ដល់ស្អែកឡើងបាន២-៣ថ្ងៃបាន ប្រលែងឲ្យធ្វើការ ។

ដារ៉ាៈ ពេលដែលត្រឡប់មកពីគាខ្មៅ?

ហ៊ៈ បាទៗ មកពីទួលស្លែងវិញនឹង បាមឲ្យយើងបានប្រហែល២-៣ថ្ងៃបានឲ្យយើងធ្វើការ ប៉ុន្តែយប់វាដាក់ច្រវ៉ាក់វិញដដែល ថ្ងៃយើងប្រលែង រត់ចេញពីកន្លែងនឹងបានមកព្រែកហូរ ព្រែកអាទាំងហើយដឹកអាប្រឡាយនៅរហូតសព្វថ្ងៃ អាប្រឡាយធំៗ ប៉ះដើមត្នោតដឹកដើមត្នោតចោល ប៉ះអីដឹកនឹងចោល ហើយម៉ាថ្ងៃម៉ាយប់នឹង ម៉ាថ្ងៃក្នុងពេលថ្ងៃឲ្យឈប់តែម៉ាម៉ោងទេ ម៉ាព្រឹកតាំងពីម៉ោង៣រហូតដល់ម៉ោង១១ឡើងស៊ីបាយនឹង ។

ដារ៉ាៈ ៣ព្រលប់ ៣ពេលព្រឹកយើងនឹង?

ហ៊ៈ បាទ! ៣ពេលព្រឹក ៣យប់នឹងឡើងដឹកទាល់រហូតដល់ម៉ោង១២ ។

ដារ៉ាៈ ថ្ងៃត្រង់?

ហ៊ៈ បាទ! ថ្ងៃត្រង់ បានឈប់ស៊ីបាយហើយ ម៉ោង១ចូលធ្វើវិញ ចូលធ្វើនឹងដល់ម៉ោង៥ ៗកន្លះស៊ីបាយហើយធ្វើរហូតដល់ម៉ោង ជួនកាលទៅឆ្ងាយដល់ម៉ោង១២យប់ ។

ដារ៉ាៈ គិតទៅគេងបាន៣-៤ម៉ោង?

ហ៊ៈ បាទៗ ប៉ុននឹងឯង ម៉្លេះហើយៗបាយនឹងហូបអញ្ចឹងដែរ ហូបបានម៉ាចានដាក់ត្រកួនទេ អត់មានបានច្រើនទេ បានត្រឹមប៉ុននឹងដួសម៉ាចានៗប៉ុននឹងម្នាក់ហូបទៅ ។

ដារ៉ាៈ អាចានៗ របៀបចានចង្កឹះនឹង?

ហ៊ៈ បាទ! ចានចង្កឹះនឹង ចានចង្កឹះយើងនឹង ប៉ុនៗនឹងម្នាក់ទេ ។

ដារ៉ាៈ អាចពេញទេ?

ហ៊ៈ ត្រឹមតែមាត់ៗ អត់មានបានមួយក្រពុំទេ ត្រឹមប៉ុននឹងហើយ ម៉្លេះហើយហូបគ្មានកើតៗ ហើយឆ្កួមៗហើយដំបៅ ព្រោះដំបៅដែលចេញពីក្នុងស្រះដំបៅលិចៗយើងនឹង តាមជើងប្អូនមិនជឿមើលសព្វថ្ងៃនៅរហូតស្នាមដល់សព្វថ្ងៃ អានេះឈ្មោះដំបៅចេះៗស៊ីតាមកំភួនជើងរហូតដល់សព្វថ្ងៃ ។

ដារ៉ាៈ ហើយកាលធ្វើប្រឡាយធ្វើអីនឹង ឡូកឡំជាមួយអ្នកទោសក្នុងនឹង ឬមួយក៏ប្រជាជនទូទៅ?

ហ៊ៈ អត់ទេ អ្នកទោសទាំងអស់អ្នកទោសខបមាដូចជាទាហាន ដូចជាយោធាអីអញ្ចឹងណា គេ

បញ្ជូនទៅកន្លែងនឹង ស្រាប់នេះនឹងគេបញ្ជូនយកមកឲ្យធ្វើការនៅនឹងទាំងអស់ អត់មានជាមួយប្រជាជនទេ ។

ដារ៉ា : អត់មែនជាមួយប្រជាជនទេ?

ហ៊ី : បាទ!អត់ទេ ។

ដារ៉ា : គឺចំរុះជាមួយអ្នកទោសនៅនឹងទាំងអស់?

ហ៊ី : បាទ! តាខ្មៅនឹង បាទ!អ្នកទោសនឹងទាំងអស់ ។

ដារ៉ា : កាលនៅទួលស្លែង ពូមានពួកខ្មែរក្រហមគេឲ្យហូបចុកម៉េចដែរ ពេលនៅទួលស្លែង?

ហ៊ី : អានឹងវាចែករបបឲ្យយើងម៉ាចានៗអញ្ចឹងដែរ តែម៉ាចានៗអញ្ចឹងទេឲ្យមានលើស២ចាន ៣ចានអត់មានទេ តែម៉ាចានៗម្នាក់មួយចាន មិនមែនអាប្រធានគេណា ប្រធានគុកនឹងគេ អ្នកយាមគុកនឹងគេ បាយមួយកំធន់អញ្ចឹងមក គេដួសវាស់ចែកឲ្យម៉ាចានៗហុចដាក់តំរៀបគ្នាអញ្ចឹងទៅ ហើយយើងចូលទៅដើរយកម្នាក់មួងអញ្ចឹងទៅ ។ បើអ្នកណាដើរអត់រួចទេ អ្នកណាទោសស្រាលនឹង វាឲ្យអ្នកទោសស្រាលនឹងមកយកឲ្យអ្នកទោសធ្ងន់ អានេះ អាអ្នកដែលជាប់ខ្នោះ វាចេញម្នាក់អីមកយកដើរដាក់ចែកឲ្យអញ្ចឹងទៅណា ។

ដារ៉ា : កាលហូបចុកនឹង មកហូបនៅក្នុងរោង ឬក៏នៅណា?

ហ៊ី : ហូបនៅក្នុងគុកនឹងបណ្តោយ នៅកន្លែងនឹង នៅកន្លែងជាប់ខ្នោះនឹង បត់ជើងនឹងហូបនឹងដេកនឹង អត់មានដាក់ចម្ងាយបានប្រហែល១ម៉ែត្រ ២ម៉ែត្រ ៣ម៉ែត្រអត់ទេ ឃ្នោះដែលវាតំរៀបយើងតាមជញ្ជាំងក្នុងបន្ទប់អញ្ចឹងប្អូន ដាក់អាឡាំងកេះគ្រាប់នឹងមួយសម្រាប់យើងបត់ជើងនៅនឹងទៅ ដាក់នៅជាប់នឹងចុងជើងយើងនឹង ចុងជើងជាប់ខ្នោះអញ្ចឹងដាក់ចុងជើងនឹងទៅ ហើយបាយយកមកហូបនៅនឹងជាមួយគ្នានឹង ។ យើងមានទាកទៅណារួច បើប្រលែងយើងបានហូបនេះហូបនោះ អានេះដាក់ខ្នោះអញ្ចឹងដល់ពេលឡើងអង្គុយស៊ីនឹងទៅ ។

ដារ៉ា : ពេលជាប់ខ្នោះនឹង អត់មានជាប់ខ្នោះដៃទេ?

ហ៊ី : អត់ទេ វាប្រលែងខ្នោះដៃ ជាប់ខ្នោះជើងដាក់កងទាំងពីរ ។

ដារ៉ា : ហើយមានស្លៀកពាក់អី ជាប់ខ្លួនទេ ពេលដែលជាប់ជាឃ្នោះអញ្ចឹង?

ហ៊ី : តែខោអាវយើងមួយកំប្លេរដែលជាប់ខ្លួនប៉ុន្មាននៅប៉ុននឹងទាំងអស់ អត់មានបានយកទៅឲ្យបោក ឲ្យគក់ឲ្យអីអត់មានទេ ចែរហូត ចៃស៊ីដំបៅខាំ អាចៃសាច់នោះ ។ ចុះយើងមានបានបោកទឹកអីណាប្អូន រាប់ខែរាប់ឆ្នាំអីនឹង អត់មានបាន ។ ដល់ពេលដែលមុជទឹកអញ្ចឹងទៀត

ដែរ វាមិនមែននេះទេ មិនបានឲ្យយើងទៅបោកខោ បោកអាវចេញទេ វាបណ្តើរទាំងឃ្នោះ ដាក់មួយច្រវ៉ាក់ៗដាក់ម៉ាខ្សែអញ្ចឹងទៅឲ្យយើងដើរបណ្តើរយើងទៅណា ។

ដារ៉ា : ជាប់គ្នាម៉ង?

ហ៊ី : បាទ! ជាប់គ្នា ។

ដារ៉ា : មិនមែនដាច់ដោយឡែកទេ?

ហ៊ី : អត់មានដាច់ដោយឡែកទេ ដាក់ម៉ាខ្សែ ដាក់ម៉ាច្រវ៉ាក់វែងអញ្ចឹងទៅ បណ្តើរទៅដល់អញ្ចឹង ។

ដារ៉ា : ហើយដល់ពេលមុជទឹក?

ហ៊ី : មុជទឹកវាចាក់ម្តងមួយដល់ពេលក្បាលប្រាស់ទឹកនឹងវាចាក់ប្រលែងម្តងមួយឲ្យមកមុជឈូសៗ ដាក់ចូលវិញ បានពិបាកវេទនាណាស់ ។

ដារ៉ា : អាពេលថ្ងៃពូ ព្រោះអ្នកទោសនឹងឲ្យធ្វើអីទៅពេលថ្ងៃ?

ហ៊ី : ពេលថ្ងៃដែលយើងនៅជាប់ខ្នោះនឹងតែម្តង ។

ដារ៉ា : នៅមើលគ្នាម៉ង?

ហ៊ី : បាទ!នៅអញ្ចឹងម៉ង នៅតែអញ្ចឹងនៅជាប់ជើងខ្នោះជាប់ជើង ។

ដារ៉ា : ក្នុងបន្ទប់ទាំងអស់គ្នា ទាំងវែង?

ហ៊ី : បាទ!ក្នុងបន្ទប់ទាំងអស់ ឧបមាមាផ្ទះពេញអញ្ចឹងដាក់ទល់ជើងគ្នាអញ្ចឹង លាន់ច្រវ៉ាក់ម៉ាតិចក៏អត់បាន និយាយគ្នាក៏អត់បានដែរ ឡើងមកវើ ដេកអញ្ចឹងដែរ ដេកមិនបានចុះម៉ាអាណុងដែកវាអញ្ចឹង វាត្រូវការមនុស្សច្រើន យើងមិនអាចដេកសន្ទឹងចេញៗពុតខ្លួនបានទេ ជួនកាលដេកបញ្ចិត ហើយជើងជាប់ប៉ុនៗនឹងទៅ ។ បានពិបាកណាស់ប្អូនអើយ ខ្ញុំក៏មិននឹកស្មានថាអាយុខ្ញុំថ្ងៃបាននៅរហូតដល់សព្វថ្ងៃនេះដែរ នៅរហូតដល់សព្វថ្ងៃនេះ បានថាការឈឺចាប់នេះដល់ហើយ ខ្ញុំមែនទែនហើយណា ។

ដារ៉ា : ហើយតាំងពីពូរត់មកដល់កន្លែងតាខ្មៅទៅពួកខ្មែរក្រហមបញ្ជូនចេញទៅធ្វើការ ជីកប្រឡាយតាមព្រែកហូរអីអញ្ចឹង?

ហ៊ី : បាទៗ ។

ដារ៉ា : ហើយពេលនឹងពូលួចរត់ម្តងទៀត?

ហ៊ី : បាទ! លួចរត់ ដាច់ចិត្តរត់ហើយ ព្រោះថាវាដល់ហើយបាយក៏អត់ឆ្អែត បាយក៏ធ្វើដល់ទៀតក៏ខ្ញុំឡើងបេះព្រីង អញ្ចឹងខ្ញុំឃើញភ្នំជីរសូរនឹងនៅខាងត្បូងព្រែកហូរ ព្រែកអាទាំងនឹង ខ្ញុំឃើញលឹមៗតូចៗព្រោះខ្ញុំស្គាល់ច្បាស់ដែរ អាយុយើងប៉ុននឹងហើយយើងអាចចាំហើយ

អាចដឹងដែរណា ឃើញភ្នំនឹងតូចមើលភ្នំអី ភ្នំជីសូរ ។ ដល់ពេលព្រលប់ដែលវាឲ្យស៊ីបាយ ហើយរៀបឲ្យដឹកប្រឡាយទៀត ព្រលប់ៗនឹងណា ក៏ខ្ញុំមានពួកម៉ាក់ខ្ញុំមួយដែលជិតស្និតគ្នា នៅដេកជាមួយគ្នាអីមួយគ្នា ។

ដារ៉ា : ឈ្មោះអីនឹង?

ហ៊ី : ក៏ភ្លេចឈ្មោះដែរ បែបវាក៏ស្លាប់បាត់ហើយអានឹង មិននៅទេ ។

ដារ៉ា : ម៉េចបានពូសន្និដ្ឋានថាស្លាប់នោះ?

ហ៊ី : ព្រោះថាវា ចុះវាស្គមដល់ហើយ ឈឺគ្នាឈឺផង គ្នាឈឺទៀត ក៏ថា«ឥឡូវឯងរត់ទេ» ហឺ!ក៏វាឆ្លើយថា«អញអត់ហ៊ានរត់ទេ អើយខ្លាចម្តងទៀត» ថា«ឥឡូវបើឯងមិនហ៊ានរត់ទេ បើអាណាសួរអត់ថាអញទៅឈឺអាចម៍» ខ្ញុំកាន់បានដងវែកមួយ ហើយនឹងបង្គីរ ខ្សែគោមួយ កន្ទុយ ខ្ញុំជាៗព្រៃខ្ញុំរត់បានម៉ាតិច មកជួបអាឆ្លងហែលស្ទឹងព្រែកហូរនឹង ។ ក្រោយមកទៀតពូសួរសម្លេងថាស្រែកព័ទ្ធអញ្ចឹងណា មនុស្សរត់ហើយរើយ ។ ហើយក៏ពេលនឹងវាយប់ៗនឹងព្រៃក៏ខ្ញុំពួននឹង ទៅដល់យប់កណ្តាលអាធ្រាតស្ងាត់ បានខ្ញុំដើរទៅទៀត ។ ដើរទៀតដល់ជិតភ្លឺ ខ្ញុំរកព្រៃពួនដេក ។

ដារ៉ា : ហើយបានចំណីចំណុកម៉េច?

ហ៊ី : បានដែរ បានឃើញផ្លែព្រីងដើរទៅជួបនឹងដើមឈើអញ្ចឹងក៏ឃើញអានេះស្គាល់ដើមព្រីង ផ្លែខ្មៅៗខែនឹងវាខែចែត្រ ខែផ្លែព្រីងទុំនឹង បាទ!អានេះអាចចាំថា អានេះផ្លែព្រីង ក៏ខ្ញុំខែភ្លឺបេះក៏ខ្ញុំឡើងម៉េចផ្លែព្រីងដាក់ខ្ទក់ បានម៉ាខ្ទក់ពីរខ្ទក់ បានដាក់ត្រៀមទុកស៊ីបេះ ។ ដល់ដើរដល់ជិតភ្លឺ រកកន្លែងពួនដេក ថ្ងៃអត់ហ៊ានដើរទេ ដើរដល់ម៉ាយប់ទៀតបានទៅដល់ភ្នំជីសូរ ។ ឃើញថាអានេះភ្នំជីសូរ ជួបក្មេងៗឃ្វាលគោ កូននឹងក៏វាសួរ«ពូឯងទៅណា?» ក៏កុហកវាថា«គេឲ្យពូឃ្វាលគោ» ចុះយើងមានខ្សែគោ «ឲ្យឃ្វាលគោ ឥឡូវគោវាដាច់បាត់ហើយ ឥឡូវនេះអញទៅតាមចាប់គោនៅតំបន់២៥វិញ» តំបន់យើង អាផ្ទះយើងឃុំព្រែកស្តី ភូមិព្រែកស្តីនឹង ក៏វាហៅចូលស៊ីបាយនៅកន្លែងមន្ទីរសហករណ៍នឹង ខ្ញុំខ្លាចជាប់មកទៀត ខ្ញុំថា«អត់ស៊ីទេប្រញាប់ណាស់» ក៏ប្រុចរត់មកបណ្តោយ ក្រោយមកទៀត មកដល់យប់នៅកណ្តាលវាលខ្សៀវដែលខាងលិចចំព្រែកស្តីមកលិច គេមានហៅវាលខ្សៀវមួយមានដើមពោធិ៍ធំ... ខ្ញុំឃើញផ្លែឪឡឹកគេដាំទាំងចំការៗ ក៏ដាច់ចិត្តខ្ញុំហាវខ្លាំងពេក ចុះបើព្រលប់ទៀតនោះ អត់ឃើញអ្នកយាមទៀតក៏បេះបានផ្លែឪឡឹក២ៗយកទៅស៊ីដេកដើរអត់ដល់ផ្ទះទៀត ទៅដេកនៅនឹងព្រៃនឹងទៅដេកនៅកណ្តាលព្រៃនឹង ម៉ាយប់ទៀតស្អែកឡើងបានរសៀលៗតាមព្រៃ បានហែល

ឆ្លងតាមស្ទឹងក្បាលខ្មោចយើងមានស្ទឹងមួយចុះទៅអន្គរនឹង ឆ្លងអាស្ទឹងមួយទៀតនឹងហែលអត់ហ៊ាននេះទេ ហែលកាត់ព្រៃខ្វ ទៅទម្រាំដល់ព្រៃនឹងបានខ្ញុំដើររសៀលចូលឡើងដល់ផ្ទះខ្ញុំហើយដល់ផ្ទះបងៗក៏គេឲ្យទៅធ្វើការអីបាត់អត់ក៏គេបិទទ្វារជិតអស់ ចុះខ្ញុំឡើងតាមជញ្ជាំង ។ ក៏ខ្ញុំឡើងទៅឃើញបាយបងនៅបាតឆ្នាំងនឹង ហើយស្វាយទុំខំស៊ីៗមែនទែនទៅ ក៏បងខ្ញុំមកពីធ្វើការនឹងក៏ស្រែកហៅចែ ថាអាណាក៏ហៅឈ្មោះខ្ញុំ ខ្ញុំថានេះគាត់ក៏យំហូរបណ្ដោយ គាត់ថា«ស្មានតែឯងងាប់បាត់ហើយ» ។ បានមកដល់ផ្ទះទៀត ប្អូនឯងដឹងម៉េច កាលខ្មោចឪពុកខ្ញុំគាត់នៅ ចែខ្ញុំគាត់ប្រាប់ថា«ឥឡូវវាមកហើយ នៅពួកនៅផ្ទះដែលទាឯងមកយកវាផង» ដល់ពេលមកយកទៅ ពេលដែលបាយប្អូនអំណាចដែលខ្ញុំឃ្លានខ្លាំងពេក ម៉ាឆ្នាំងលេខ៣ខ្ញុំហូបអស់ ឃ្លានខ្លាំងពេក គាត់ចេះយកបាយលាក់ឯណាក៏ខ្ញុំទៅរុះរើរកឃើញយកមកស៊ីៗឲ្យងាប់ចោលអំណាចឃ្លានពេក ពិបាកណាស់ប្អូនអើយ ។

ដារ៉ា : ពេលឪពុកពូមកជួបមុនដឹបូងអញ្ចឹង គាត់ថាម៉េចទៅ នាំយកទៅណាទៅណៃ?

ហ៊ា : គាត់យំ នាំទៅពួកក្នុងផ្ទះ ។

ដារ៉ា : ផ្ទះរបស់ឪពុកវិញម្ដង?

ហ៊ា : បាទ! ផ្ទះរបស់ឪពុកវិញម្ដង ពួននៅនឹងលើផ្ទះអត់ហ៊ានចុះដីទេ បត់ជើងបត់អីនឹងក៏លើផ្ទះនឹងដែរ ។

ដារ៉ា : អត់ដែលអត់ចេញសោះ?

ហ៊ា : អត់ចេញសោះ លែងចេញសោះ រួចហើយដាច់ចិត្តនឹងពេលនឹងមួយ គាត់មិនមានកាលនឹងគាត់នេះដែរ ក៏គាត់មានជាងឈ្នួលនឹងៗសម័យអាពតនឹងវាធ្វើការឃុំ ។ បានវាធ្វើការឃុំក៏គាត់ដាច់ចិត្ត ព្រោះខ្ញុំចេះតែពួនលើផ្ទះនឹងផ្ទះធំ ពួនលើផ្ទះក្រែងលរអផ្សុកនឹងពេក «អញមិនដឹងគិតធ្វើម៉េច ព្រោះវាចេះតែអើតលើមៗចេះ មិនដឹងធ្វើម៉េចទេ ដល់វាមកដល់ផ្ទះឯងគិតធ្វើម៉េច» ក៏គណៈឃុំវានឹងថា«ចុះលោកបងឯងទៅភ័យអី បើខ្ញុំមកសួរខ្ញុំឆ្លើយថាអត់ឃើញទៅ មិនរួចចេះ» ។

ដារ៉ា : អញ្ចឹងឈ្នួលរបស់ឪពុកពូនឹង កាលដល់ពេលសម័យខ្មែរក្រហមធ្វើមេឃុំ?

ហ៊ា : ធ្វើមេឃុំ ។

ដារ៉ា : មេឃុំព្រែកស្ដីនឹង?

ហ៊ា : បាទ! មេឃុំព្រែកស្ដីនឹង បានដល់ខ្ញុំរត់មកផ្ទះហើយនឹង មិនដឹងគិតធ្វើម៉េចក៏គាត់ទៅប្រាប់គេនឹង ។

ដារ៉ា ៖ ប្រាប់ប្រធានឃុំនឹងម៉ង?

ហ៊ិ ៖ ឈ្មោះហ៊ិន ឥឡូវគេយកទៅវ៉ៃចោលបាត់ហើយហ៊ិន នៅជាប់ស្ពានព្រែកពង់ខាងត្បូងកន្លែងផ្ទះប្អូនអញ្ជើញទៅផ្ទះខ្ញុំថ្ងៃមុន គេយកទៅវ៉ៃចោលបាត់ហើយ ។

ដារ៉ា ៖ ដល់ពេលមេឃុំនឹងដឹងថាពូនៅផ្ទះនឹងដែរ?

ហ៊ិ ៖ បាទ! ដឹងចុះប្រាប់គេត្រង់ហើយ ដឹងហើយ ។

ដារ៉ា ៖ ហើយមានគេមកតាមទេ កាលជំនាន់នឹង?

ហ៊ិ ៖ ទេ! មានគេមកតាមដែរនឹង គាត់អត់មានបានឃើញមកអីទេ គេក៏ស្មានថាខ្ញុំស្លាប់បាត់ទៅក៏គេលេងឈប់តាមទៅ លួមម៉ាស្ងាត់ទៅក៏គេបញ្ជូនឲ្យទៅសហករណ៍យើង ។

ដារ៉ា ៖ បញ្ជូនចូលទៅក្នុងសហករណ៍នៅក្នុងឃុំព្រែកស្ដី?

ហ៊ិ ៖ បាទ! ឃុំព្រែកស្ដីនឹង

ដារ៉ា ៖ ហើយធ្វើការធ្វើងារអីអញ្ចឹង សហករណ៍នឹងគេឆ្ងល់គេអីទេ គេអត់មានឆ្ងល់អីទេ?

ហ៊ិ ៖ គេមិនអាចដេញដោលយើងបានទេ ។ ព្រោះថាសម័យនឹងគេមិនអាចទៅដឹកឫសដឹកគល់អីណាអ្នកណា ធ្វើអីឲ្យតែគេឲ្យធ្វើចេះតែធ្វើទៅ ។ មកនឹងចេះតែវេទនាទៀតណា វេទនាទៀតមិនមែនវេទនអីវេទនារហូត ។

ដារ៉ា ៖ វាជាទូទៅអារឿងពិបាកនឹង?

ហ៊ិ ៖ បាទ! ជារឿងទូទៅ កាលសម័យនឹងបាទ! ។

ដារ៉ា ៖ ហើយរយៈពេលប៉ុន្មានទៅបានបែកភ្នំពេញម្ដងទៀត ចូលមក៧៩នឹង?

ហ៊ិ ៖ យូរដែរ កាលខ្ញុំបាននឹងហើយ បាទខ្ញុំបានយាយនេះបណ្ដោយនៅយូរបានប្រហែលម៉ាឆ្នាំ ។

ដារ៉ា ៖ នៅណា?

ហ៊ិ ៖ នៅព្រែកស្ដីនឹង បាទ! ។

ដារ៉ា ៖ ពេលដែលបែកហើយ ឬក៏នៅក្នុងសម័យអាពត?

ហ៊ិ ៖ នៅក្នុងសម័យអាពតនឹងបណ្ដោយ ។

ដារ៉ា ៖ រត់មកបានប៉ុន្មានឆ្នាំ?

ហ៊ិ ៖ រត់មកប្រហែលម៉ាឆ្នាំអីនឹងបានៗយាយនេះ រត់បានម៉ាឆ្នាំ បានបែកៗនេះបណ្ដោយ ។

ដារ៉ា ៖ ពេលរៀបចំគ្រួសារ រៀបចំសម័យខ្មែរក្រហម?

ហ៊ិ ៖ សម័យអាពត ។

ដារ៉ា ៖ បាទ! សម័យអាពត ។ ហើយភូមិឃុំអីគេរៀបចំ?

ហ៊ី ៖ កាលរៀបឲ្យនឹងកាលនឹងប៉ុន្មានគូ?

ប្រពន្ធ ៖ កាលរៀបឲ្យនឹង២៥គូ ។

ដារ៉ា ៖ ២៥គូ?

ហ៊ី ៖ បាទ!

ដារ៉ា ៖ ហើយមានស្នើ មានអីទេមុននឹង?

ហ៊ី ៖ គេចាប់ដាក់ឲ្យយើង គេចាប់ដាក់ឲ្យ ។

ដារ៉ា ៖ ហើយកាលនឹងដូចថាខាងឃុំគេរៀបចំមកអញ្ជើងម៉ង?

ហ៊ី ៖ បាទ! គេរៀបចំឲ្យអញ្ជើងតាមគូណាៗហៅដាក់ៗបណ្តោយ ។

ដារ៉ា ៖ អញ្ជើងពេលបាន ពូបានគ្រួសារហើយប្រហែលម៉ាឆ្នាំបានបែកភ្នំពេញ?

ហ៊ី ៖ បាទ! ប្រហែលមិនដល់មួយឆ្នាំទេ ប្រហែលដើមខែ ដាងពាក់កណ្តាលខែ ការហើយបាន យាយហើយបានគេបញ្ជូនទាំងយាយទាំងអីទៅដកទៅធ្វើការនៅណាចុងព្រែក ចុងអី ។

ដារ៉ា ៖ នេះជាការសោកស្តាយម្យ៉ាងដែរ ពេលដែលពូជាប់នៅទួលស្លែងទួលអីទៀតទៅពូអត់សូវ បានចាំថាអ្នកណាឈ្មោះអីស្ទួរពូ ហើយមេគុកមេអីពូអត់ដែលពុទេ?

ហ៊ី ៖ បាទ! អត់ ។

ដារ៉ា ៖ អត់សោះ?

ហ៊ី ៖ បាទ! អត់ ។

ដារ៉ា ៖ អត់មានចាំអីទេ?

ហ៊ី ៖ បាទ! អត់ចាំ ។

ដារ៉ា ៖ ចុះដល់ពេលឥឡូវពុថាគាត់ទោសឌុច គាត់ទោសអី ពូដឹងថាឌុចនឹងជាប្រធានគុកទួលស្លែងនឹង ដែរឬយ៉ាងម៉េចកាលនឹង?

ហ៊ី ៖ បានដឹងដែរតើក្មួយ ព្រោះថាមិនអញ្ជើងបានរស់ដល់សព្វថ្ងៃ ។

ដារ៉ា ៖ ហើយកាលពេលមិញដានីបានសួរនាំពូច្រើនដែរ ពីប្រវត្តិដើមរបស់ពូដែរ ហើយដូចថាមាន ឈ្មោះមនុស្សមួយចំនួននៅក្នុងនឹង ពូនៅចាំខ្លះដែរ?

ហ៊ី ៖ ចាំមនុស្សដែលសូត្រនឹងខ្ញុំបានចាំៗឈ្មោះ ព្រោះស្គាល់ឈ្មោះពាង ឈ្មោះឆាំងនឹង ។

ដារ៉ា ៖ ឈ្មោះឆយអីនឹង?

ហ៊ី ៖ អាឆយនឹង មុនខ្ញុំស្គាល់ដែរ ប៉ុនផាប់បាត់ហើយអាឆយនឹងផាប់បាត់អស់ហើយ ។

ដារ៉ា ៖ គីម ឆាំង?

ហ៊ា : គីម ឆាំងអញ្ចឹង អត់មានបានឃើញវិលមកផ្ទះវិញទេ ផ្ទះនៅព្រែកតាឌួង អត់មានបានវិលមកផ្ទះវិញទេ ។

ដារ៉ា : ចុះដី គាត?

ហ៊ា : អានឹងដូចគ្នា ទៅបាត់រហូត ។

ដារ៉ា : ចុះពេលដែលពូ បែក៧៩មកវិល ពូធ្លាប់ទៅផ្ទះពីរនាក់នឹងដែរ?

ហ៊ា : ទៅៗ ព្រោះផ្ទះបងខ្ញុំនឹងនៅជិតនឹងដែរ ។

ដារ៉ា : អញ្ចឹងឈ្មោះឆាង ឈ្មោះគាងអីសុទ្ធតែនៅភូមិលោកពូ?

ហ៊ា : បាទៗ ហ៎ា!គេភូមិព្រែកតាឌួង យើងនៅព្រែកស្តី ប៉ុន្តែផ្ទះបងនៅព្រែកតាឌួងដែរ ខ្ញុំធ្លាប់ចេញចូលនៅជិតនឹង កាលយើងនៅនឹង ។

ដារ៉ា : ចុះបានបញ្ជាក់ប្រាប់បងប្អូន?

ហ៊ា : បាទ! ប្រាប់អស់ហើយ អត់មានឃើញវិលត្រឡប់មកវិញទេ ។

ដារ៉ា : នេះកាលនឹងមានចម្លើយពូដែរ ដូចធ្វើនៅឆ្នាំ៧៥ ខែវិច្ឆិកា ថ្ងៃទី១០ គេដាក់ម៉ោង៧យប់ ហើយក្នុងនេះ គេចុះឈ្មោះថាឈ្មោះចៀម អ្នកអភិបាលស៊ើបអង្កេតនឹងណា?

ហ៊ា : អញ្ចឹង! យើងក៏មិនបាននេះ យើងដែលអញ្ចឹងលោកក្មួយ ។

ដារ៉ា : ហើយនេះមានចម្លើយបន្ថែម មានចម្លើយលើកទី២ឆ្នាំ៧៥ដែរ ខែវិច្ឆិកាដដែល តែថ្ងៃទី២២ អានេះម៉ោង១៩ ៗនឹងម៉ោង៧យប់ដែរ ។

ហ៊ា : បាទ! ចុះសួរយប់មុនមានដែរ សំបុត្រមានដែលសួរថ្ងៃអី ។

ដារ៉ា : អញ្ចឹងចម្លើយសារភាពរបស់ពូនេះ មិនមែននៅទួលស្លែងទេ?

ហ៊ា : សួរ បាទ! ហ្នឹងនៅអាកត់បញ្ជាក់នឹង ក្នុងសៀវភៅនេះ បើមិនបញ្ជាក់ទេ មិនមែនអាកន្លែងគុកធំយើងវាមិនអាចដោះលែងយើងមកបានទេ សៀវភៅនេះណា ព្រោះណាអាគ្រាៗគ្រាន់សួរចម្លើយ អត់មានកត់កំនត់ហេតុទេ អត់មានកត់កំណត់ហេតុ គ្រាន់តែសួរយើងគោលចង់ គោលៗអញ្ចឹងបានដល់កន្លែងធំគេបោះត្រាទៀតហើយ ។

ដារ៉ា : អញ្ចឹងចម្លើយសារភាពនេះ តែនេះតាមមើលមកដល់ទួលស្លែងនេះ គេដោះលែងពូថ្ងៃ៨ ខែ៣ ឆ្នាំ៧៦ ខែនឹងពូ?

ហ៊ា : បាទៗ ខែហ្នឹង ។

ដារ៉ា : ហើយអានេះ ចម្លើយនេះ មួយនេះប្រហែលជានៅទួលស្លែងតាមមើល ។

ហ៊ី ៖ បាទ! ទួលស្លែង ព្រោះសៀវភៅនេះ សៀវភៅតាមខ្ញុំចំណាំមើលដែលនៅតាមតាខ្មៅអី គេអត់មានដាក់បោះត្រាអញ្ចឹងៗ គ្រាន់កត់សៀវភៅតូចៗ សៀវភៅចេះៗទេ ។ បាទ! គ្រាន់អញ្ចឹងទេ អត់មានយកសៀវភៅចេះៗយកមកកត់ទេ ។

ដារ៉ា ៖ អត់មានក្រដាសអីអញ្ចឹងទេ?

ហ៊ី ៖ បាទ!

ដានី ៖ ចុះពូពេលដែល អ្នកដែលទៅនៅក្នុងគុកទួលស្លែង ពេលដែលជាប់ជាមួយពូ ពេលដែលនៅក្នុងបន្ទប់អីនឹង ពូមានស្គាល់អ្នកណាដែលមកពីស្រុកភូមិជាមួយពូអី ពូមាន?

ហ៊ី ៖ អត់មានទេៗ បាទ! ។

ដានី ៖ ចុះពូអ្នកដែលសួរចម្លើយពូដែលថាហុចបារីឲ្យពូនឹង កាលនឹងពូមានចំណាំមុខ មានដូចថា ឃើញមុខគេចំណាំថាពួកគាត់មកពីខាងណាអី?

ហ៊ី ៖ មិនដឹងដែរ អត់បានដឹង មិនដឹងមកពីខាងណា ។

ដានី ៖ ចុះពូពេលនឹងមានគេដូចថាហៅពូទៅថតរូប ថតអីមានទេ?

ហ៊ី ៖ ដូចអត់ទេ ក្មួយអត់មានថតរូបទេ ។

ដានី ៖ អត់មានថតរូបទេ?

ហ៊ី ៖ បាទៗ ។

ដានី ៖ អញ្ចឹងពេលដែលពូរត់មកដល់ផ្ទះវិញហើយ មានដែលឃើញគណៈឃុំនឹងឡើបប្រាប់ថា មានខាងពីខាងមន្ទីរនៅតាខ្មៅគេមកតាមពូមកវិញទេ?

ហ៊ី ៖ គេមកតាម គាត់ប្រាប់ដែរថាគេមករកៗអញ្ចឹង គាត់ក៏ឆ្លើយថាអត់មានបានឃើញមកទេ បានខ្ញុំបានរួចខ្លួនមករហូតនឹង ។

ដានី ៖ គេប្រាប់ៗពេលណាទៅ ពេលពូមកផ្ទះនឹង?

ហ៊ី ៖ មកផ្ទះនៅពួនលើផ្ទះនឹង ខ្មោចឪពុកខ្ញុំគាត់ទៅប្រាប់គណៈឃុំនឹង ថា«ខ្ញុំវិលត្រឡប់មកដល់ផ្ទះវិញហើយ ឯងគិតធ្វើយ៉ាងម៉េច» ក៏គណៈឃុំប្រាប់ថា«ធ្វើយ៉ាងម៉េច បើវាមកហើយឲ្យវាមកទៅ ស៊ីសងលើខ្ញុំ បើខ្ញុំថាអត់ឃើញអត់ហើយវាចេះ បានខ្ញុំបានរួចខ្លួនហើយ ។

ដានី ៖ ប៉ុនគណៈឃុំនឹងគេប្រាប់ថាគេមកតាមពូនឹង តាមនៅពេលណា ពេលពូរត់មកផ្ទះបានប៉ុន្មាន?

ហ៊ី ៖ មករយៈបានប្រហែលម៉ោអាទិត្យអីដែរនឹង ។

ដានី ៖ បានប្រហែលម៉ាអាទិត្យ?

ហ៊ី ៖ បាទ!

ដានី ៖ គេប្រាប់ គាត់គណៈឃុំប្រាប់ថាខាងអ្នកណាមកតាម?

ហ៊ី ៖ ថាពួកយោធា គេមកតាម ។

ដានី ៖ គេមកតាមគេថាម៉េច?

ហ៊ី ៖ គេមកសួរមានស្គាល់ មានឃើញឈ្មោះខ្ញុំមកដល់ផ្ទះទេ បានគាត់ថាអត់មានឃើញទេ អត់មានអ្នកណាឃើញត្រឡប់មកវិញទេ បានគេឈប់តាមខ្ញុំរបូតទៅ ។

ដានី ៖ គេតាមតែម្ដងនឹងទេ?

ហ៊ី ៖ បាទ! តាមតែម្ដងនឹងទេ ។

ដារ៉ា ៖ ពីមុនមកពូធ្លាប់និយាយរឿងរ៉ាវនឹងប្រាប់កូនចៅអីដែរពូ?

ហ៊ី ៖ ខ្ញុំប្រាប់តែយាយៗ តែបងប្អូនៗនៅផ្ទះឪពុកក្មេកម្ដាយក្មេកក៏គាត់អត់ដឹងដែរ ។

ដារ៉ា ៖ ហើយពូធ្លាប់តាមដានរឿងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមអីដែរ?

ហ៊ី ៖ បាទ! គ្រាន់បានព្ញសួរប្រកាស គ្រាន់នឹកឃើញដែរ មានការចុកចាប់ដែរនឹង ឈឺចាប់ក៏មិនអាចអធ្យាស្រ័យបានដែរ មិនអញ្ចឹងលោកក្អួយព្រោះថាវាធ្វើយើងដល់ហើយវាចេះ ខ្ញុំក៏មិនអាចថាលើកលែងឲ្យបានដែរ ព្រោះថាខ្ញុំគ្មានកំហុសអីសោះ គ្រាន់តែកំហុសឲ្យទៅដោះដែកដូចជាទៅដោះដែករឿងនឹងខ្ញុំទៅគ្រាំទ្រមិនបានឲ្យទៅវៃស្លាប់ ខ្ញុំគ្រាំទ្រមិនបានខ្ញុំរត់តែប៉ុននឹងហើយធ្វើអំពើអញ្ចឹង កាត់ទោសទៅសមស្របតាមកំហឹងរបស់ខ្ញុំដែរលោកក្អួយ ។

ដានី ៖ ពូនៅព្រៃកស្តី ពូស្គាល់ពូហ៊ុយទេ នៅអន្ទង់សាននោះ ទាបនោះ?

ហ៊ី ៖ អត់ៗស្គាល់ផង ។

ដានី ៖ អត់ស្គាល់ទេ?

ហ៊ី ៖ បាទ!អត់ស្គាល់ទេ ។

ដានី ៖ អត់ដែលឃើញ អត់ស្គាល់គាត់ទេ?

ហ៊ី ៖ បាទ! មិនដែលទាំងឃើញ ។

ដារ៉ា ៖ ដែលមានពេលថ្ងៃអី ពួកអ្នកយាមអ្នកអីនៅទួលស្លែងឲ្យពូចេញក្រៅម្ដងម្កាល?

ហ៊ី ៖ អត់ៗ ។

ដារ៉ា ៖ ម៉ារយៈពេលម៉ាជាប់គុក?

ហ៊ី ៖ បាទ! ម៉ាជាប់គុកអត់មានសោះ ឲ្យនៅតែនឹងឃ្នោះ សូម្បីតែឡើងឈរនឹង ក៏ឡើងវាមិនរួចផង នៅតែអង្គុយនឹងទៅ ហើយឃ្នោះនឹងដំបៅដំបៀរស៊ីអញ្ចឹងទៅ ដំបៅដល់ឆ្អឹង ដល់ពេលដែលទៅដល់គុកទួលស្លែងនឹង វាប្រលែងឲ្យខ្ញុំនៅ ។

## កាសែតទី២ ផ្នែក«ក»

ហ៊ិ : ដេកទៅមានប៉ុន្មាន ម៉ាបន្ទប់ដាក់ម្នាក់ៗ អញ្ចឹងប្អូនណា ហើយចានបាយគេមានប្រឡោះតូចមួយនឹង គេសម្រាប់រុញចានបាយចូលតាមនឹង ។

ដារ៉ា : មានប្រឡោះទៀត?

ហ៊ិ : រកកន្លែងមនុស្សចេញមិនរួចនឹង ។

ដារ៉ា : មានទឹកមានអីជាមួយនឹងទៅ?

ហ៊ិ : ទឹកគេរិញដាក់ឲ្យ ។

ដារ៉ា : ហើយចេះអាចបន្តជីវិតបានដែរ?

ហ៊ិ : បាទ! ចេះអាយុវាមិនថ្លៃ ខ្ញុំគ្មានថារស់បានទេ ប្រហែលម៉ាជិនាន់នឹងខុសពីខ្ញុំដូចគ្មានពីណារស់ ចុះឃើញវៃដែលអ្នកស្រុកកើត ពីឆ្នាំ៧៥ វៃ៧៥ យើងរួចហើយប្រជាជនយើងមិនទាន់នៅធ្វើកោះខែកោះអីណា អាកន្លែងតំបន់មន្ទីរ១៥វាមិនទាន់នេះទេ នៅប្រជាជនគេស៊ីបាយឯកជនណា ក៏ឃើញខ្ញុំគេវៃខ្ញុំឡើងសន្លប់អញ្ចឹងគេអូសៗខ្ញុំណា ក៏គេមកប្រាប់ខ្មោចឪពុកខ្ញុំនេះថាវាងាប់បាត់ហើយអញ្ចឹង ។

ដារ៉ា : អញ្ចឹងឪពុកពូមានមកតាមអីទេ?

ហ៊ិ : អត់ទេ គ្មានសិទ្ធិមកតាមបានទេ អត់មានទៅណាបានទេ ។

ដារ៉ា : អញ្ចឹងបានមានចេះតែបាត់កូនចៅប្រជាជនដែលចូលបដិវត្ត?

ហ៊ិ : បាទ! ចូលបដិវត្ត បាទ! ។

ដារ៉ា : ដឹងថា?

ហ៊ិ : បាត់ដំណឹង ដឹងទៅណាមកណា ។

ដារ៉ា : ដឹងថាមូលហេតុអី មិនដឹងជាអ្នកណាដឹង អ្នកណាឃើញអីអញ្ចឹង?

ហ៊ិ : ព្រោះដូចខ្ញុំរៀបរាប់ បើសិនជាឧបមាយើងជាប់គុកនឹង ក៏យើងមិនអាចនិយាយឆ្លើយឆ្លងគ្នាបាន ឬមួយសួរសាក់ទុក្ខគ្នាអត់បានទេ យើងនៅកន្លែងជាប់គុកនៅកន្លែងម៉ង់វាចេះ មិនអាចថាឯងជាប់គុកនៅភូមិណា នៅផ្ទះកន្លែងណា មិនអាចសួរបានទេ ។

ដារ៉ា : អាចដឹងសួរនាំអ្នកណាដែលអាចដឹងបានដល់ថ្នាក់ថា?

ហ៊ិ : បើវាដាច់ខ្សែរយៈអស់ហើយ ដូចខ្ញុំនេះឧបមាថាខ្ញុំមិនអាចបន្តបានព្រោះថាបិទជិតត្រឹមខ្ញុំហើយ ព្រោះខ្ញុំឮថាប្អូនសួរខ្ញុំថាមានស្គាល់ពីណាពីណែទៀត សូម្បីតែជាប់គុកវាមិនឲ្យយើងនិយាយជាមួយគ្នាផង ឥឡូវអ្នកឯងៗនៅភូមិណា ឃុំណា វាបិទយើងកន្លែងនឹងម៉ង់ ។

ដារ៉ា ៖ អញ្ចឹងខ្ញុំដូចអស់សំនួរដែរពូ ហើយអរគុណពូច្រើនដែលជួយរៀបរាប់រឿងផ្ទាល់ខ្លួនរបស់ពូណា ។ ហើយនៅក្នុងបទសម្ភាសន៍នេះ ពួកខ្ញុំសុំការអនុញ្ញាតិលោកពូយកប្រើប្រាស់ក្នុងការសរសេរអត្ថបទ ការស្រាវជ្រាវបន្តទៅទៀតអីបានអត់អីទេ?

ហ៊ី ៖ បានៗក្មួយបាន អត់អីមានការឈឺចាប់ នឹងឲ្យលោកក្មួយជួយបង្ហាញប្រវត្តិដែលជួរចត់នឹងទៅប្រាប់ក្មេងជំនាន់ក្រោយ ហើយនឹងឲ្យយើងរំលឹក ហើយចាំយើងបង្ហាត់ក្មេងជំនាន់ក្រោយដែលអំពើឈឺចាប់ដូចយើងនឹងកុំឲ្យត្រឡប់មកវិញ ។

ដារ៉ា ៖ បាទ! អញ្ចឹងខ្ញុំអរគុណពូច្រើន ។

«ចប់»